ឯកសារចុងក្រោយមិនទាន់ផ្សព្វផ្សាយ

ចែកចាយទូទៅ
២៧ កក្កដា ២០២០
ឯកសារដើម៖ អង់គ្លេស

**គណៈកម្មាធិការសិទ្ធិមនុស្ស**

# សេចក្ដីអធិប្បាយទូទៅ លេខ ៣៧

## មាត្រា ២១ ៖ សិទ្ធិជួបប្រជុំដោយសន្តិវិធី*

## I. ការកត់សម្គាល់ទូទៅ

១. សិទ្ធិមនុស្សជាមូលដ្ឋាននៃការជួបប្រជុំដោយសន្តិវិធី ផ្ដល់លទ្ធភាពឲ្យបុគ្គលគ្រប់រូបបញ្ចេញមតិរបស់ខ្លួនរួមគ្នា និងចូលរួមក្នុងការរៀបចំសង្គមរបស់ខ្លួន។ សិទ្ធិជួបប្រជុំដោយសន្តិវិធីមានសារសំខាន់ណាស់ក្នុងសិទ្ធិរបស់វាផ្ទាល់ ដោយសារថាសិទ្ធិនេះការពារសមត្ថភាពរបស់មនុស្ស ក្នុងការអនុវត្តស្វ័យភាពបុគ្គលក្នុងសាមគ្គីភាពជាមួយអ្នកដទៃ។ រួមជាមួយនឹងសិទ្ធិពាក់ព័ន្ធដទៃទៀត សិទ្ធិនេះ ក៏ជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធអភិបាលកិច្ចដែលមានការចូលរួម ដោយផ្អែកលើលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ និងពហុនិយម។ ការជួបប្រជុំដោយសន្តិវិធី អាចដើរតួយ៉ាងសំខាន់មួយក្នុងការអនុញ្ញាតឲ្យអ្នកចូលរួមបំផុសគំនិត និងគោលដៅដែលប្រាថ្នាចង់បានក្នុងវិស័យសាធារណៈ និងបង្កើតវិសាលភាពនៃការគាំទ្រ ឬការប្រឆាំងទៅនឹងគំនិតណានិងគោលដៅទាំងនោះ។ ករណីដែលសិទ្ធិទាំងនេះ ត្រូវបានប្រើដើម្បីដោះស្រាយការកើតទុក្ខមិនសុខចិត្ត ការជួបប្រជុំដោយសន្តិវិធីអាចបង្កើតឱកាសសម្រាប់ការដោះស្រាយភាពមិនចុះសម្រុងគ្នាប្រកបដោយបរិយាប័ន្ន និងដែលមានការចូលរួមដោយសន្តិវិធី។

២- ម្យ៉ាងវិញទៀត សិទ្ធិជួបប្រជុំដោយសន្តិវិធីគឺជាឧបករណ៍ដ៏មានតំលៃមួយ ដែលអាចប្រើ និងត្រូវបានប្រើ ដើម្បីទទួលស្គាល់ និងសម្រេចសិទ្ធិផ្សេងៗទៀត រាប់បញ្ចូលទាំងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ សិទ្ធិនេះ មានសារៈសំខាន់ជាពិសេស ចំពោះបុគ្គល និងក្រុមដែលត្រូវបាត់បង់បានឱកាស។ ការខកខានមិនបានគោរព និងធានាសិទ្ធិជួបប្រជុំដោយសន្តិវិធីគឺជាសញ្ញាសំគាល់ពីការបង្ក្រាប។

៣- ប្រយោគទី១ នៃមាត្រា២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា" សិទ្ធិប្រជុំដោយសន្តិវិធី ត្រូវតែទទួលស្គាល់" ។ សិទ្ធិត្រូវបានបញ្ជាក់ក្នុងន័យស្រដៀងគ្នា នៅក្នុង

* អនុម័តដោយគណៈកម្មាធិការនាសម័យប្រជុំលើកទី១២៩ របស់ខ្លួន ២៩ មិថុនា)ដល់ ២៤ កក្កដា ២០២០។ (

ឧបករណ៍អន្តរជាតិផ្សេងទៀត[1] ហើយខ្លឹមសាររបស់វាត្រូវបានបញ្ជាក់ដោយស្ថាប័នអន្តរជាតិផ្សេងៗ ឧទាហរណ៍នៅក្នុងទស្សនៈរបស់ពួកគេ សេចក្តីសង្កេតចុងក្រោយ សេចក្តីសម្រេចចិត្ត សេចក្តីណែនាំ ការបកស្រាយ និងការសំរេចចិត្តរបស់តុលាការ។[2] ក្រៅពីត្រូវបានចងភ្ជាប់ដោយច្បាប់អន្តរជាតិ ដើម្បីទទួលស្គាល់សិទ្ធិជួបប្រជុំដោយសន្តិវិធី រដ្ឋភាគច្រើនលើសលុបក៏ទទួលស្គាល់សិទ្ធិនេះនៅក្នុងរដ្ឋធម្មនុញ្ញជាតិរបស់ពួកគេផងដែរ។[3]

៤- សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី ការពារការជួបប្រជុំដោយអហិង្សា ដោយបុគ្គលទាំងឡាយសម្រាប់គោលបំណងជាក់លាក់ ពោលគឺការជួបជុំគ្នាដែលមានលក្ខណៈបញ្ចេញមតិ។[4] សិទ្ធិនេះ បង្កើតបានជាសិទ្ធិបុគ្គលមួយ ដែលត្រូវបានអនុវត្តរួមគ្នា។[5] ដូច្នេះ ជាប់នឹងសិទ្ធិនេះ គឺជាធាតុផ្សំនៃការផ្សារភ្ជាប់។

៥- មនុស្សគ្រប់រូបមានសិទ្ធិជួបប្រជុំដោយសន្តិវិធី៖ ប្រជាពលរដ្ឋ និងមិនមែនជាពលរដ្ឋ ដូចគ្នា។ សិទ្ធិនេះ អាចត្រូវបានអនុវត្តដោយ ឧទាហរណ៍ ជនបរទេស[6] ជនចំណាកស្រុក (មានឯកសារ ឬគ្មានឯកសារ)[7] អ្នកស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួន[8] ក៏ដូចជាជនគ្មានរដ្ឋ។

---

[1] សូមមើល ឧទា. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា២០ (១)) អនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស) (មាត្រា១១) អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (មាត្រា១៥) និងធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជន (មាត្រា១១)។ ធម្មនុញ្ញអារ៉ាប់ស្តីពីសិទ្ធិមនុស្សការពារសិទ្ធិប្រជាជន (មាត្រា២៨)។ កាតព្វកិច្ចជាក់លាក់ទាក់ទងនឹងការចូលរួមក្នុងការជួបប្រជុំដោយសន្តិវិធី ក៏អាចមាននៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា១៥) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (មាត្រា៥ (ឃ) (ix)) និងធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិ និងសុខុមាលភាពកុមារ (មាត្រា៨) ។

[2] ឧទាហរណ៍ពីយន្តការក្នុងតំបន់ សូមមើលការិយាល័យអង្គការសន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) សម្រាប់ស្ថាប័នប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស និងគណៈកម្មការអឺរ៉ុបសម្រាប់លទ្ធិប្រជាធិបតេយ្យតាមរយៈច្បាប់ (គណៈកម្មការក្រុងវេនី) *គោលការណ៍ណែនាំស្តីពីសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីលើកទី៣* (២០១៩) គណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្សនិងប្រជាជន (ACHPR) គោលការណ៍ណែនាំស្តីពីសេរីភាពខាងសមាគម និងការជួបប្រជុំនៅទ្វីបអាហ្វ្រិក (២០១៧) ACHPR គោលការណ៍ណែនាំស្តីពីការឃ្លាំមើលការជួបប្រជុំដោយមន្ត្រីអនុវត្តច្បាប់នៅអាហ្វ្រិក (២០១៧) ការិយាល័យអ្នករាយការណ៍ពិសេស ស្តីពីសេរីភាពក្នុងការបញ្ចេញមតិរបស់គណៈកម្មការអន្តរអាមេរិកាំង អំពីសិទ្ធិមនុស្ស ការតវ៉ា និងសិទ្ធិមនុស្ស៖ ស្តង់ដារស្តីពីសិទ្ធិដែលពាក់ព័ន្ធនឹងការតវ៉ាសង្គម និងកាតព្វកិច្ច ដើម្បីដឹកនាំការឆ្លើយតបរបស់រដ្ឋ (២០១៩) ។

[3] ចំនួនសរុប១៨៤ ក្នុងចំណោមសមាជិកចំនួន១៩៣ នៃអង្គការសហប្រជាជាតិ ទទួលស្គាល់សិទ្ធិជួបជុំដោយសន្តិវិធីនៅក្នុងរដ្ឋធម្មនុញ្ញរបស់ពួកគេ សូមមើល www.rightofassembly.info.

[4] សូមមើល *ឃីវិនម៉ា និងហ្វាំងឡង់* (CCPR/C/50/D/412/1990) កថាខណ្ឌ៧.៦ *សេឃីកូ និងបេឡារុស្ស* (CCPR/C/109/D/1851/2008) កថាខណ្ឌ ៩.៣ និង *ផូផ្លាវនី និងបេឡារុស្ស* (CCPR/C/118/D/2139/2012) កថាខណ្ឌ៨.៥ ។

[5] សូមមើល សេចក្តីផ្តល់មតិយោបល់ទូទៅលេខ៣១ (២០០៤) កថាខណ្ឌ៩ ។

[6] សូមមើល សេចក្តីផ្តល់មតិយោបល់ទូទៅលេខ១៥ (1986) កថាខណ្ឌ១-២ និង CCPR/C/KWT/CO/3 កថាខណ្ឌ ៤២។

[7] CCPR/C/DOM/CO/6 កថាខណ្ឌ៣២។

[8] CCPR/C/NPL/CO/2 កថាខណ្ឌ១៤។

៦- មាត្រា២១ ការពារការជួបប្រជុំដោយសន្តិវិធី ទោះជាធ្វើឡើងនៅទីណាក៏ដោយ៖ នៅក្រៅផ្ទះ ក្នុងផ្ទះ និងតាមអនឡាញ នៅទីសាធារណៈ និងឯកជន ឬនៅកន្លែងទាំងពីរនេះរួមបញ្ចូលគ្នា។ ការជួបប្រជុំបែបនេះ អាចមានច្រើនរូបភាព រួមទាំង ការធ្វើបាតុកម្ម ការតវ៉ា ការប្រជុំ ការដើរដង្ហែរ ការហែរក្បួន ការអង្គុយនៅនឹងកន្លែង ការជួបជុំគ្នាអុចទៀនក្រោយសុរិយាអស្តង្គត និងការជួបប្រជុំរយៈពេលខ្លីសម្រាប់តែអិនធឺណិត និងបណ្តាញសង្គម ។ សកម្មភាពទាំងនេះ ត្រូវបានការពារក្រោមមាត្រា២១ មិនថាពួកគេនៅនឹងកន្លែង ដូចជា ការឈរនៅខាងក្រៅកន្លែងធ្វើការ ឬចល័ត ដូចជាការដង្ហែរក្បួន ឬការហែក្បួន ជាដើម។

៧. ក្នុងករណីជាច្រើន ការជួបប្រជុំដោយសន្តិវិធីមិនឈានដល់គោលដៅចម្រូងចម្រាសទេ ហើយបណ្តាលឲ្យមានការរំខានតិចតួច ឬគ្មានផងកសឹងមាន។ គោលបំណងនេះប្រហែលជា ជាឧទាហរណ៍ ដើម្បីអបអរសាទរទិវាជាតិ ឬអបអរលទ្ធផលនៃព្រឹត្តិការណ៍កីឡា។ ទោះជាយ៉ាងណាក៏ដោយ ការជួបប្រជុំដោយសន្តិវិធីជួនកាលអាចត្រូវបានប្រើ ដើម្បីស្វែងរកគំនិត ឬគោលដៅដែលមានភាពប្រទាំងប្រទុងគ្នា ។ កម្រិត ឬចរិតលក្ខណៈនៃការជួបប្រជុំទាំងនោះ អាចបណ្តាលឲ្យមានការរំខានខ្លះ ឧទាហរណ៍ចរាចរណ៍រថយន្ត ឬការដើរថ្មើរជើង ឬសកម្មភាពសេដ្ឋកិច្ច។[9] ផលវិបាកទាំងនេះ មិនថាមាន ឬគ្មានចេតនាក្តី វាមិនចោទជាបញ្ហាចំពោះការការពារដល់សកម្មភាពជួបប្រជុំទាំងនោះឡើយ។ មិនថាកំរិតប៉ុណ្ណា ដែលព្រឹត្តិការណ៍អាចបង្កើតឲ្យមានការរំខាន ឬហានិភ័យបែបនេះ ត្រូវតែគ្រប់គ្រងក្នុងក្របខ័ណ្ឌនៃកតិកាសញ្ញានេះ។

៨. ការទទួលស្គាល់សិទ្ធិជួបប្រជុំដោយសន្តិវិធី ដាក់កាតព្វកិច្ចដែលត្រូវគ្នាទៅលើរដ្ឋភាគីទាំងឡាយ ក្នុងការគោរព និងធានាការអនុវត្តរបស់ខ្លួន ដោយគ្មានការរើសអើង។[10] នេះតម្រូវឲ្យរដ្ឋអនុញ្ញាតឲ្យការជួបប្រជុំបែបនេះ កើតឡើងដោយគ្មានការជ្រៀតជ្រែកដោយគ្មានហេតុផល និងដើម្បីជួយសម្រួលដល់ការអនុវត្តសិទ្ធិ និងការពារអ្នកចូលរួម។ ប្រយោគទីពីរ នៃមាត្រា២១ ផ្តល់នូវមូលដ្ឋានសម្រាប់ការរឹតត្បិតដែលអាចកើតមាន ប៉ុន្តែការរឹតត្បិតបែបនេះ ត្រូវតែមានលក្ខណៈតូចចង្អៀត។ តាមពិតមានដែនកំណត់លើការរឹតត្បិតដែលអាចធ្វើទៅបាន។

៩- ការការពារពេញលេញនៃសិទ្ធិជួបប្រជុំដោយសន្តិវិធី គឺអាចធ្វើទៅបាន លុះត្រាតែនៅពេលដែលសិទ្ធិដទៃទៀត ជារឿយៗមានត្រួតស៊ីគ្នា ក៏ត្រូវបានការពារដែរ ជាពិសេស សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការចូលរួមជាសមាគម និងការចូលរួមក្នុងជីវភាពនយោបាយ។[11] ការការពារសិទ្ធិជួបប្រជុំដោយសន្តិវិធីច្រើនតែពឹងផ្អែកផងដែរទៅលើការធ្វើឲ្យប្រសើរឡើងនូវសិទ្ធិពលរដ្ឋ និងនយោបាយ ក៏ដូចជា សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ ឧទាហរណ៍ នៅពេលដែលឥរិយាបថរបស់បុគ្គលដាក់សិទ្ធិទាំងនេះនៅក្រៅវិសាលភាពនៃការការពារដោយមាត្រា២១ ជាអាទិ៍ ដោយសារតែពួកគេធ្វើសកម្មភាព

---

[9] CCPR/C/KOR/Q/4 កថាខណ្ឌ២៦។

[10] ICCPR មាត្រា២ (១) ។

[11] Cf. A/HRC/39/28, para. 14.

ហិង្សា ពួកគេរក្សាសិទ្ធិផ្សេងទៀតរបស់ខ្លួន នៅក្រោមកតិកាសញ្ញា ជាកម្មវត្ថុនៃការ កម្រិតកំណត់ និងការរិតត្បិត។

១០. របៀបដែលការជួបប្រជុំ ត្រូវបានធ្វើ និងបរិបទរបស់ពួកគេផ្លាស់ប្ដូរតាមពេលវេលា។ បញ្ហានេះអាចប៉ះពាល់ដល់របៀបដែលអាជ្ញាធរបានចាត់វិធានការ។ ឧទាហរណ៍ បច្ចេកវិទ្យាទំនាក់ទំនងដែលកំពុងរីកចម្រើន ផ្ដល់នូវកាលានុវត្តភាពដល់ការចាប់ផ្ដុំទាំងមូល ឬមួយផ្នែកតាមអនឡាញ ហើយជាញឹកញាប់ ដើរតួសំខាន់ក្នុងការរៀបចំ ការចូលរួម និងការតាមឃ្លាំមើលការជួបប្រជុំជារូបវន្ត ដែលមានន័យថាការជ្រៀតជ្រែកជាមួយការប្រាស្រ័យទាក់ទងបែបនេះ អាចរារាំងការជួបប្រជុំ។ នៅពេលដែលបច្ចេកវិទ្យាឃ្លាំមើល អាចត្រូវបានគេប្រើ ដើម្បីរុករកការគំរាមកំហែងនៃអំពើហឹង្សា ហើយដូច្នេះ ដើម្បីការពារសាធារណៈជន ពួកគេក៏អាចរំលោភលើសិទ្ធិឯកជន និងសិទ្ធិផ្សេងទៀតរបស់អ្នកចូលរួម និងអ្នកឈរមើល និងមានឥទ្ធិពលមិនល្អ។ លើសពីនេះទៅទៀត មានការកើនឡើងនូវភាពជាម្ចាស់ឯកជន និងទម្រង់នៃការគ្រប់គ្រងផ្សេងទៀត លើទីធ្លាប្រើប្រាស់ជាសាធារណៈ និងវេទិកាទំនាក់ទំនង។ ការពិចារណាលើតម្រូវការទាំងនេះ ចាំបាច់ត្រូវមានការយល់ដឹងបែបសហសម័យអំពីក្របខ័ណ្ឌគតិយុតនៃមាត្រា២១។

## II. វិសាលភាពនៃសិទ្ធិជួបប្រជុំដោយសន្តិវិធី

១១. ការកំណត់ថាតើការចូលរួមរបស់នរណាម្នាក់ នៅក្នុងការជួបប្រជុំមួយ ត្រូវ ឬមិនត្រូវបានការពារដោយមាត្រា២១ តម្រូវឲ្យមានដំណើរការជាពីរដំណាក់កាល។ ជាបឋម គេត្រូវតែបានមើលថាតើសកម្មភាពរបស់បុគ្គលណាម្នាក់ ស្ថិត ឬមិនស្ថិតក្នុង*វិសាលភាព*នៃការការពារ ដែលត្រូវបានផ្ដល់ដោយសិទ្ធិ ដែលមានន័យថា វាជាការចូលរួមដែលស្ថិតក្នុង" ការជួបប្រជុំដោយសន្តិវិធី" ឬទេ (ដូចដែលបានពិពណ៌នានៅក្នុងផ្នែកនេះ) ។ ប្រសិនជាស្ថិតក្នុងវិសាលភាពនេះ រដ្ឋត្រូវតែគោរព និងធានាសិទ្ធិរបស់អ្នកចូលរួម (ដូចមានចែងក្នុងផ្នែកទី៣) ។ ទីពីរ ត្រូវមើលថាតើ*ការរឹតត្បិត*ណាមួយ ទៅលើការអនុវត្តសិទ្ធិនេះមានភាពស្របច្បាប់ ឬទេ នៅក្នុងបរិបទនោះ (ដូចដែលបានពិពណ៌នានៅក្នុងផ្នែកទី៤) ។

១២. ការចូលរួមក្នុង " ការជួបប្រជុំ" តម្រូវឲ្យរៀបចំ ឬចូលរួមក្នុងការជួបប្រជុំមនុស្សសម្រាប់គោលបំណង ដូចជា ការបញ្ចេញមតិផ្ទាល់ខ្លួន ការបង្ហាញពីជំហរមួយលើបញ្ហាណាមួយជាក់លាក់ ឬការផ្លាស់ប្ដូរគំនិត។ ការជួបប្រជុំនេះ ក៏អាចមានគោលបំណង ដើម្បីអះអាង ឬបញ្ជាក់ពីសាមគ្គីភាព ឬអត្តសញ្ញាណក្រុមផងដែរ។ ក្រៅពីមានគោលបំណងបែបនេះ ការជួបប្រជុំអាចបម្រើគោលដៅផ្សេងទៀត ដូចជា ការកំសាន្ត វប្បធម៌ សាសនា ឬគោលបំណងពាណិជ្ជកម្ម ហើយនៅតែត្រូវបានការពារដោយមាត្រា២១ ជាដដែល។

១៣. ទោះជាសំដៅដល់សញ្ញាណនៃការជួបប្រជុំក្តី ក៏ត្រូវតែមានអ្នកចូលរួមលើសពីម្នាក់ដែរ នៅក្នុងការជួបប្រជុំនេះ[12] អ្នកតវ៉ាតែម្នាក់ទទួលបានការការពារដោយប្រៀបធៀបក្រោមកតិកាសញ្ញានេះ ឧទាហរណ៍ក្រោមមាត្រា១៩។ ទោះបីជាការអនុវត្តសិទ្ធិជួបជុំដោយសន្តិវិធី ជាធម្មតា ត្រូវបានគេយល់ថាទាក់ទងទៅនឹងការជួបប្រជុំមនុស្សជារូបវន្ត មាត្រា២១ ការការពារត្រូវបានពង្រីកវិសាលភាពផងដែរដល់ការចូលរួមពីចម្ងាយ ក្នុងការរៀបចំ និងការជួបប្រជុំ ឧទាហរណ៍ តាមអនឡាញ។[13]

១៤- ការជួបប្រជុំដោយសន្តិវិធីច្រើនតែរៀបចំទុកជាមុន ដែលទុកពេលឲ្យអ្នករៀបចំជូនដំណឹងដល់អាជ្ញាធរឲ្យរៀបចំតាមការចាំបាច់។ ទោះយ៉ាងណាក៏ដោយ ការជួបប្រជុំនៅពេលតែមួយ ការឆ្លើយតបដោយផ្ទាល់ជាធម្មតាចំពោះព្រឹត្តិការណ៍បច្ចុប្បន្ន ទោះបីមាន ឬគ្មានការសម្របសម្រួល ត្រូវបានការពារស្មើភាពគ្នា ដោយមាត្រា២១។ ការជួបប្រជុំបែបប្រឆាំង កើតឡើងនៅពេលដែលការជួបប្រជុំមួយ ធ្វើឡើងសម្តែងមតិប្រឆាំងជំទាស់នឹងការជួបប្រជុំមួយទៀត។ ការជួបប្រជុំទាំងពីរនេះ អាចស្ថិតនៅក្នុងវិសាលភាពនៃការការពារដោយមាត្រា២១ ។

១៥. ការជួបប្រជុំដោយសន្តិវិធី មានភាពផ្ទុយគ្នាទៅនឹងការប្រជុំប្រជុំមួយដែលមានចរិតលក្ខណៈបែបអំពើហិង្សារាលដាល និងធ្ងន់ធ្ងរ។ ដូច្នេះពាក្យថា "សន្តិវិធី" និង "អហិង្សា" ត្រូវបានគេប្រើជំនួសគ្នានៅក្នុងបរិបទនេះ។ សិទ្ធិជួបប្រជុំដោយសន្តិវិធី បើតាមនិយមន័យ មិនអាចត្រូវបានអនុវត្តដោយប្រើអំពើហិង្សាបានឡើយ។ "អំពើហឹង្សា" នៅក្នុងបរិបទនៃមាត្រា២១ ជាធម្មតា បង្ហាញពីការប្រើប្រាស់ ដោយអ្នកចូលរួម នូវកម្លាំងបាយប្រឆាំងនឹងអ្នកដទៃទៀត ដែលអាចបណ្តាលឲ្យមានរបួស ឬស្លាប់ ឬខូចខាតទ្រព្យសម្បត្តិយ៉ាងធ្ងន់ធ្ងរ។[14] ការគ្រាន់តែជំរុញ និងដើរប្រជ្រៀតគ្នា ឬការរំខានដល់សកម្មភាពធ្វើដំណើររបស់យានយន្ត ឬអ្នកថ្មើរជើង ឬសកម្មភាពប្រចាំថ្ងៃ មិនមានន័យថាជា "អំពើហឹង្សា" ទេ។

១៦. ប្រសិនជាការប្រព្រឹត្តរបស់អ្នកចូលរួម ក្នុងការជួបប្រជុំមួយធ្វើឡើងដោយសន្តិវិធី ការដែលលក្ខខណ្ឌតម្រូវនៃច្បាប់ជាតិ ទាក់ទងទៅនឹងការជួបប្រជុំមួយ មិនត្រូវបានបំពេញដោយអ្នករៀបចំ ឬអ្នកចូលរួម មិនជាជាកំហុសរបស់ខ្លួនឯងផ្ទាល់ ដោយដាក់អ្នកចូលរួមនៅខាងក្រៅវិសាលភាពនៃការការពារដោយមាត្រា ២១។[15] ការមិនគោរពរបស់ប្រជាពលរដ្ឋជាសមូហភាព ឬយុទ្ធនាការដោយសកម្មភាពផ្ទាល់ អាចត្រូវបានគ្រប់ដណ្តប់ដោយមាត្រា២១ ប្រសិនបើសកម្មភាពនោះ ធ្វើឡើងដោយអហិង្សា។[16]

---

[12] *ខូលមែន និងអូស្ត្រាលី* (CCPR/C/87/D/1157/2003) កថាខណ្ឌ៦.៤ ។

[13] A/HRC/41/41

[14] សូម *មើល* OSCEនិងគណៈកម្មការវេនី *គោលការណ៍ណែនាំស្តីពីសេរីភាពក្នុងការជួបប្រជុំដោយសន្តិភាព* កថាខណ្ឌ៥១។

[15] សូមមើល តុលាការសិទ្ធិមនុស្សអឺរ៉ុប *ហ្វ្រមគីន និងរុស្ស៊ី* (ពាក្យសុំលេខ ៧៤៥៦៨/១២) សាលក្រម ចុះថ្ងៃទី៥ ខែមករា ឆ្នាំ ២០១៦ កថាខណ្ឌ៩៧ ។

[16] សូមមើល CCPR/C/CHN-MAC/CO/1 កថាខណ្ឌ១៦។

១៧. ជានិច្ចជាកាល មិនមានខ្សែបន្ទាត់បែងចែកច្បាស់លាស់រវាងការជួបប្រជុំដែលមានលក្ខណៈសន្តិវិធី និងការជួបប្រជុំដែលមិនមានលក្ខណៈសន្តិវិធី ប៉ុន្តែមានការសន្មតជាមុន ក្នុងការគាំទ្រដល់ការចាត់ទុកការជួបប្រជុំមួយដែលនឹងប្រព្រឹត្តទៅដោយសន្តិវិធី។[17] ម្យ៉ាងវិញទៀត អំពើហឹង្សាដាច់ដោយឡែកដោយអ្នកចូលរួមមួយចំនួន មិនគួរត្រូវបានចាត់ទុកថាជាអំពើហឹង្សារបស់អ្នកដទៃទៀត អ្នករៀបចំកម្មវិធី ឬការប្រប្រជុំដូចនោះឡើយ។[18] ដូច្នេះ អ្នកចូលរួមខ្លះ នៅក្នុងការជួបប្រជុំមួយ អាចត្រូវបានគ្រប់ដណ្តប់ដោយមាត្រា២១ ខណៈដែលអ្នកផ្សេងទៀត នៅក្នុងការជួបប្រជុំតែមួយនេះ មិនគ្រប់ដណ្តប់ដោយមាត្រានេះទេ។

១៨. សំណួរថាតើការជួបប្រជុំមួយមានលក្ខណៈសន្តិវិធី ឬយ៉ាងណានោះ ត្រូវតែឆ្លើយដោយយោងទៅលើអំពើហឹង្សាដែលមានប្រភពចេញពីអ្នកចូលរួម។ អំពើហឹង្សាប្រឆាំងនឹងអ្នកចូលរួមក្នុងការប្រជុំដោយសន្តិវិធីពីសំណាក់អាជ្ញាធរ ឬ*ពីសំណាក់ភ្នាក់ងារបង្កហេតុ*ដែលធ្វើឡើងក្នុងនាមពួកគេ មិនធ្វើឲ្យការជួបប្រជុំមួយប្រែក្លាយពីសន្តិវិធីទៅជាហិង្សាបានឡើយ។ ដូចគ្នានេះអនុវត្តផងដែរ ចំពោះអំពើហិង្សាដោយសមាជិកសាធារណៈដែលប្រឆាំងទៅលើការជួបប្រជុំ ឬដោយអ្នកចូលរួមពីខាងការជួបប្រជុំដែលប្រឆាំង។

១៩. សកម្មភាពរបស់អ្នកចូលរួមមួយចំនួន នៅក្នុងការជួបប្រជុំមួយអាចចាត់ទុកថាជាអំពើហិង្សាប្រសិនជាអាជ្ញាធរអាចបង្ហាញភស្តុតាងដែលអាចជឿទុកចិត្តបានថា នៅមុនពេល ឬនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នោះ អ្នកចូលរួមទាំងនោះ កំពុងញុះញង់ឲ្យអ្នកដទៃប្រើអំពើហិង្សា ហើយសកម្មភាពបែបនេះ ទំនងជាបង្កឲ្យមានអំពើហិង្សា អ្នកចូលរួមមានចេតនាហិង្សា និងមានផែនការធ្វើសកម្មភាពហិង្សា ឬអំពើហិង្សាខាងផ្នែកពួកគេ គឺជិតមកដល់ហើយ។[19] ករណីដាច់ដោយឡែកនៃការប្រព្រឹត្តបែបនេះនឹងមិនគ្រប់គ្រាន់ ដើម្បីធ្វើឲ្យការជួបប្រជុំទាំងមូលក្លាយជាមិនសន្តិវិធីឡើយ ប៉ុន្តែប្រសិនសកម្មភាពនេះមានការរីករាលដាលជាក់ស្តែងនៅក្នុងការជួបប្រជុំ ការចូលរួមក្នុងការជួបជុំដូចនេះ មិនត្រូវបានការពារក្រោមមាត្រា២១ ទៀតឡើយ។

២០- ការដែលអ្នកចូលរួមកាន់វត្ថុដែលគេឃើញ ឬអាចគេឃើញថាជាអាវុធ ឬឧបករណ៍ការពារ ដូចជាម៉ាសការពារឧស្ម័នពុល ឬមួកសុវត្ថិភាព មិនគ្រប់គ្រាន់ដើម្បីកំណត់ពីសកម្មភាពហិង្សារបស់អ្នកចូលរួមឡើយ។ នោះគឺត្រូវកំណត់ដោយផ្អែកលើករណីនីមួយៗ ដោយផ្អែកលើ ក្នុងចំណោមចំណុចផ្សេងទៀត ច្បាប់ជាតិស្តីពីការកាន់កាំភ្លើង (ជាពិសេសអាវុធ) ការអនុវត្តវប្បធម៌ក្នុងស្រុក ថាតើមានភស្តុតាងបង្ហាញពីចេតនាហិង្សា និងហានិភ័យនៃអំពើហិង្សា ដោយវត្តមាននៃវត្ថុបែបនេះឬទេ។

---

[17] A/HRC/31/66 កថាខណ្ឌ១៨។

[18] សូមមើល តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិកាំង *ករណីស្ត្រីរងគ្រោះដោយអំពើទារុណកម្មផ្លូវភេទ ក្នុងសំណុំរឿង អាតែនកូ និងម៉ិកស៊ិកូ* សាលក្រម ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ស៊េរី C លេខ៣៧១ កថាខណ្ឌ១៧៥ តុលាការសិទ្ធិមនុស្សអឺរ៉ុប *ហ្វ្រមគីន និងរុស្ស៊ី* កថាខណ្ឌ៩៩។

[19] សូមមើល ផែនការសកម្មភាពរ៉ាបាត (២០១២) A/HRC/22/17/Add.4, appendix, កថាខណ្ឌ២៩ (ច) ។

## III. កាតព្វកិច្ចរបស់រដ្ឋភាគីទាំងឡាយ ក្នុងការគោរពសិទ្ធិជួបប្រជុំដោយសន្តិវិធី

២១. កតិកាសញ្ញានេះ កំណត់កាតព្វកិច្ចចំពោះរដ្ឋភាគីទាំងឡាយ ឲ្យ " គោរព និងធានា" សិទ្ធិទាំងអស់ ដែលមានចែងនៅក្នុងកតិកាសញ្ញានេះ (មាត្រា២ (១)) ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ និងវិធានការដទៃទៀត ដើម្បីសម្រេចគោលបំណងនេះ (មាត្រា២ (២)) និងដើម្បីបន្តគណនេយ្យភាព និងផ្តល់នូវមធ្យោបាយដោះស្រាយដ៏មានប្រសិទ្ធភាពសម្រាប់ការរំលោភលើសិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញា (មាត្រា ២ (៣))។[20] ដូច្នេះ កាតព្វកិច្ចរបស់រដ្ឋភាគី ទាក់ទងនឹងសិទ្ធិជួបប្រជុំដោយសន្តិវិធី រួមមានធាតុផ្សេងៗទាំងនេះ ទោះបីជាសិទ្ធិក្នុងករណីខ្លះ អាចត្រូវបានរិតត្បិតស្របតាមលក្ខណៈវិនិច្ឆ័យនៃមាត្រា២១ ក៏ដោយ។

២២. រដ្ឋទាំងឡាយ ត្រូវទុកឲ្យអ្នកចូលរួមមានសេរីភាព ក្នុងការកំណត់គោលបំណង ឬខ្លឹមសារសម្តែងមតិណាមួយនៃការប្រជុំ។ ដូច្នេះ វិធីសាស្ត្ររបស់អាជ្ញាធរចំពោះការជួបប្រជុំគ្នាដោយសន្តិវិធី និងការរិតត្បិតណាមួយ ជាគោលការណ៍ត្រូវតែជា" អព្យាក្រឹតភាពមាតិកា" [21] និងមិនផ្អែកលើអត្តសញ្ញាណរបស់អ្នកចូលរួម ឬទំនាក់ទំនងរបស់ពួកគេជាមួយអាជ្ញាធរឡើយ។ ម៉្យាងវិញទៀត ទន្ទឹមនឹង " ពេលវេលា ទីកន្លែង និងរបៀបរបប" នៃការជួបប្រជុំអាចស្ថិតនៅក្រោមកាលៈទេសៈខ្លះ ជាកម្មវត្ថុនៃការរិតត្បិតស្របច្បាប់តាមមាត្រា២១ ដោយសារតែចរិតលក្ខណៈនៃការជួបប្រជុំសំដែងមតិជាធម្មតា តាមដែលអាចធ្វើទៅបាន ត្រូវអនុញ្ញាតឲ្យអ្នកចូលរួម ធ្វើការជួបប្រជុំស្ថិតក្នុងចំងាយមួយដែលទស្សនិកជនគោលដៅ " អាចមើលឃើញ និងស្តាប់ឮ" ។[22]

២៣. កាតព្វកិច្ចគោរព និងធានាឲ្យការជួបប្រជុំប្រព្រឹត្តទៅប្រកបដោយសន្តិវិធី ដាក់កាតព្វកិច្ចអវិជ្ជមាន និងកាតព្វកិច្ចវិជ្ជមានចំពោះរដ្ឋទាំងឡាយ នៅមុនពេល នៅក្នុងអំឡុងពេល និងនៅក្រោយពេលជួបប្រជុំ។ កាតព្វកិច្ចអវិជ្ជមាន តម្រូវ *មិនឲ្យមានការជ្រៀតជ្រែកមិនចាំបាច់ណាមួយ* ទៅក្នុងការជួបប្រជុំដោយសន្តិវិធី។ ឧទាហរណ៍ រដ្ឋមានកាតព្វកិច្ច មិនហាមឃាត់ រិតត្បិត រារាំង បំបែក ឬរំខានដល់ការជួបប្រជុំដោយសន្តិវិធីដោយគ្មានមូលហេតុរឹងមាំ មិនដាក់ទោសទណ្ឌដល់អ្នកចូលរួម ឬអ្នករៀបចំដោយគ្មានមូលហេតុនិត្យានុកូល។

២៤. លើសពីនេះទៀត រដ្ឋភាគីទាំងឡាយ មានភារកិច្ចវិជ្ជមានមួយចំនួន ដើម្បី*ជួយសម្រួល*ដល់ការជួបប្រជុំដោយសន្តិវិធី និងផ្តល់លទ្ធភាពឲ្យអ្នកចូលរួមអាចសម្រេចបាននូវគោលបំណងរបស់ពួកគេ។[23]

---

20 មតិយោបល់ទូទៅលេខ ៣១ ។

21 សូមមើល *អាលិចស៊ីវ និងសហព័ន្ធរុស្ស៊ី* (CCPR/C/109/D/1873/2009) កថាខណ្ឌ៩.៦ សូមមើលផងដែរ *អាមែលកូវិជ និងបេឡារុស្ស* (CCPR/C/125/D/2720/2016) កថាខណ្ឌ៦.៦ CCPR/C/GNQ/CO/1 កថាខណ្ឌ៥៤។

22 *ស្រិជកាក់ និងបេឡារុស្ស* (CCPR/C/124/D/2260/2013) កថាខណ្ឌ៦.៥ ។

23 ចាប់តាំងពីមានសេចក្តីសំរេចរបស់ខ្លួន ក្នុងករណី *ធីរចិនយ៉ាក់ និងបេឡារុស្ស* (CCPR/C/108/D/1948/2010) គណៈកម្មាធិការបានបញ្ជាក់ម្តងហើយម្តងទៀតថា វិធានការរបស់រដ្ឋក្នុងការឆ្លើយតបទៅនឹងការជួបប្រជុំមួយ " គួរតែត្រូវបានដឹកនាំដោយគោលដៅ ដើម្បីជួយសម្រួលដល់សិទ្ធិ" (កថាខណ្ឌ៧.៤)។ សូមមើលផងដែរ CCPR/C/BEN/CO/2 កថាខណ្ឌ ៣៣ សូមមើល A/HRC/20/27 កថាខណ្ឌ ៣៣ សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស៣៨/១១ OP ៤ ។

ដូច្នេះ រដ្ឋទាំងឡាយ ត្រូវលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ការអនុវត្តសិទ្ធិជួបប្រជុំ ដោយសន្តិវិធីដោយគ្មានការរើសអើង ហើយដាក់ចេញនូវក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ដែលអាចឲ្យការអនុវត្តសិទ្ធិប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។ ជួនកាល វិធានការជាក់លាក់មួយចំនួន អាចនឹងតម្រូវឲ្យមានទៅលើផ្នែកខាងអាជ្ញាធរ។ ឧទាហរណ៍ ពួកគេអាចនឹងត្រូវបិទផ្លូវ បង្វែរទិសចរាចរណ៍ ឬផ្តល់សន្តិសុខសុវត្ថិភាព។ ក្នុងករណីចាំបាច់ រដ្ឋទាំងឡាយ ក៏ត្រូវតែ*ការពារ*អ្នកចូលរួមផងដែរ មិនឲ្យមាន ការរំលោភបំពានដែលអាចកើតមាន ពីសំណាក់តួអង្គមិនមែនរដ្ឋ ដូចជា ការជ្រៀតជ្រែក ឬអំពើហិង្សាពីសំណាក់សមាជិកសាធារណៈជន[24] ក្រុមបាតុករប្រឆាំង និងអ្នកផ្តល់សន្តិសុខឯកជន។

២៥. រដ្ឋទាំងឡាយ ត្រូវតែធានាថា ច្បាប់ និងការបកស្រាយ និងការអនុវត្តច្បាប់របស់ពួកគេ មិនបណ្តាលឲ្យមានការរើសអើង ក្នុងការប្រើប្រាស់សិទ្ធិជួបប្រជុំដោយសន្តិវិធី ឧទាហរណ៍ ដោយផ្អែកលើបញ្ហាពូជសាសន៍ ពណ៌សម្បុរ អាយុ ភេទ ភាសា សាសនា ឬជំនឿ ទស្សនៈនយោបាយ ឬទស្សនៈផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម កំណើត ជនជាតិភាគតិច ជនជាតិដើមភាគតិច ឬស្ថានភាពផ្សេងទៀត ពិការភាព ទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ ឬឋានៈផ្សេងទៀតឡើយ។[25] រដ្ឋភាគីទាំងឡាយ ត្រូវខិតខំប្រឹងប្រែងជាពិសេស ដើម្បីធានាឲ្យមានការសម្របសម្រួល និងការការពារដោយសមភាព និងប្រសិទ្ធភាពចំពោះសិទ្ធិជួបប្រជុំដោយសន្តិវិធីរបស់បុគ្គលទាំងឡាយ ដែលជាសមាជិកក្រុម ដែលត្រូវបានគេរើសអើង ឬជាកម្មវត្ថុនៃការរើសអើង ឬដែលអាចជួបបញ្ហាប្រឈមជាក់លាក់មួយចំនួនក្នុងការចូលរួមក្នុងការជួបប្រជុំ។[26] លើសពីនេះទៀត រដ្ឋទាំងឡាយមានកាតព្វកិច្ចការពារអ្នកចូលរួមឲ្យមានការរំលោភបំពាន ឬការរើសអើងតាមគ្រប់រូបភាព។[27]

២៦. សិទ្ធិជួបប្រជុំដោយសន្តិវិធី មិនលើកលែងអ្នកចូលរួមពីបញ្ហាប្រឈមដោយសមាជិកដទៃទៀតនៃសង្គមឡើយ។ រដ្ឋទាំងឡាយ ត្រូវគោរព និងធានាឲ្យការជួបប្រជុំប្រឆាំង ថាជាការជួបប្រជុំដែលធ្វើឡើងដើម្បីសិទ្ធិរបស់ខ្លួនផ្ទាល់ ទន្ទឹមនេះក៏ត្រូវបង្ការទប់ស្កាត់ការរារាំងមិនសមហេតុផលណាមួយនៃការជួបប្រជុំដែលពួកគេជំទាស់។[28] ជាគោលការណ៍ រដ្ឋទាំងឡាយ ត្រូវប្រកាន់យកនូវវិធីសាស្រ្តអព្យាក្រឹតភាពចំពោះមាតិកាប្រឆាំងនឹងការជួបប្រជុំប្រឆាំង ដែលត្រូវអនុញ្ញាតឲ្យប្រព្រឹត្តទៅ តាមដែលអាចធ្វើទៅបាន ស្ថិតចំងាយដែលអាចមើលឃើញ និងសំឡេងដែលអាចស្តាប់ឮនៃការជួបប្រជុំប្រឆាំងដែលពួកគេមានគោលដៅទៅលើរក។

---

[24] អាលិចស៊ីវ និងសហព័ន្ធរុស្ស៊ី (CCPR/C/109/D/1873/2009) កថាខណ្ឌ៩.៦ ។

[25] CCPR/C/GEO/CO/4 កថាខណ្ឌ៨ CCPR/C/MNG/CO/6 កថាខណ្ឌ១១ CCPR/C/RUS/CO/7 កថាខណ្ឌ១០ CCPR/C/PRY/CO/3 កថាខណ្ឌ៩ សូមមើល C.f. CRC/C/KEN/CO/3-5 កថាខណ្ឌ ២៧-២៨ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (A/RES/61/295) មាត្រា២។

[26] A/HRC/31/66 កថាខណ្ឌ.១៦

[27] CCPR/C/CHL/CO/6 កថាខណ្ឌ១៩។ សូមមើលផងដែរ *ហ្វីដូតូវា និងសហព័ន្ធរុស្ស៊ី* (CCPR/C/106/D/1932/2010) កថាខណ្ឌ១០.៤។

[28] សូមមើល តុលាការសិទ្ធិមនុស្ស វេទិកា “Ärzte für das Leben” និងប្រទេសអូទ្រីស (ពាក្យសុំលេខ10126/82) សាលក្រម ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ១៩៨៨ កថាខណ្ឌ ៣២។

២៧. លទ្ធភាពដែលថាការជួបប្រជុំដោយសន្តិវិធីអាចបង្កឲ្យមានប្រតិកម្មអវិជ្ជមាន ឬអំពើហិង្សាពីសមាជិកសាធារណៈមួយចំនួនដែលមិនមានហេតុផលគ្រប់គ្រាន់ដើម្បីហាមឃាត់ឬដាក់កម្រិតលើការប្រជុំឡើយ។[29] រដ្ឋមានកាតព្វកិច្ចចាត់វិធានការសមហេតុផលទាំងអស់ដែលមិនដាក់បន្ទុកមិនសមាមាត្រលើពួកគេដើម្បីការពារអ្នកចូលរួមទាំងអស់និងអនុញ្ញាតឲ្យការជួបប្រជុំបែបនេះប្រព្រឹត្តទៅដោយគ្មានការរំខាន។[30]

២៨. ប្រព័ន្ធច្បាប់ និងសេចក្តីសម្រេចចិត្តដែលមានមុខងារ និងមានតម្លាភាព ស្ថិតនៅជាស្នូលនៃកាតព្វកិច្ចគោរព និងធានាឲ្យមានការជួបប្រជុំដោយសន្តិភាព។ ច្បាប់ក្នុងស្រុកត្រូវទទួលស្គាល់សិទ្ធិនៃការប្រជុំដោយសន្តិវិធី កំណត់យ៉ាងច្បាស់នូវភារកិច្ច និងទំនួលខុសត្រូវរបស់មុខងារទាំងអស់ដែលពាក់ព័ន្ធ ត្រូវស្របនឹងបទដ្ឋានអន្តរជាតិ ហើយអាចទទួលបានជាសាធារណៈ។ រដ្ឋនានាត្រូវធានាឲ្យមានការយល់ដឹងជាសាធារណៈអំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ រួមទាំង នីតិវិធីដែលត្រូវអនុវត្តតាមដោយអ្នកដែលមានបំណងចង់អនុវត្តសិទ្ធិ អ្នកដែលជាអាជ្ញាធរទទួលខុសត្រូវ វិធានដែលត្រូវអនុវត្តចំពោះមន្ត្រីទាំងនោះ និងសំណងដែលអាចទទួលបានពីការរំលោភសិទ្ធិនានា។

២៩. រដ្ឋភាគីត្រូវធានាឲ្យមានការគ្រប់គ្រងដោយឯករាជ្យ និងតម្លាភាពរបស់គ្រប់ស្ថាប័នពាក់ព័ន្ធនឹងការជួបប្រជុំដោយសន្តិវិធី រាប់ទាំង តាមរយៈការទទួលបានសំណងទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព រាប់ទាំង សំណងតាមប្រព័ន្ធយុត្តិធម៌ ឬស្ថាប័នសិទ្ធិមនុស្សជាតិ ដោយមានគោលបំណងលើកស្ទួយសិទ្ធិមនុស្សមុនពេល អំឡុងពេល និងក្រោយពេលជួបប្រជុំ។

៣០. តួនាទីរបស់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស អ្នកឃ្លាំមើលការបោះឆ្នោត និងអ្នកដទៃទៀតដែលពាក់ព័ន្ធក្នុងការឃ្លាំមើល ឬរាយការណ៍អំពីការជួបប្រជុំ មានសារៈសំខាន់យ៉ាងពិសេសសម្រាប់ការទទួលបានសិទ្ធិពេញលេញក្នុងការជួបប្រជុំដោយសន្តិវិធី ហើយអ្នកទាំងនោះមានសិទ្ធិទទួលបានការការពារក្រោមកតិកាសញ្ញានេះ។[31] ពួកគេអាចមិនត្រូវហាមឃាត់មិនឲ្យ ឬដាក់កម្រិតដោយមិនត្រឹមត្រូវ ក្នុងការអនុវត្តមុខងារទាំងនេះ រាប់ទាំង ការពាក់ព័ន្ធទៅនឹងការឃ្លាំមើលសកម្មភាពរបស់មន្ត្រីអនុវត្តច្បាប់។ ពួកគេមិនត្រូវជួបនឹងការសងសឹក ឬការយាយីផ្សេងទៀតទេ ហើយឧបករណ៍របស់ពួកគេមិនត្រូវរឹបអូស ឬធ្វើឲ្យខូចខាតឡើយ។[32] ទោះបីជាការជួបប្រជុំត្រូវបានប្រកាសថាមិនស្របច្បាប់ ឬត្រូវបានបំបែកខ្ចាត់ខ្ចាយក៏ដោយ ក៏មិនអាចបញ្ឈប់សិទ្ធិត្រួតពិនិត្យបានដែរ។ វាជាការអនុវត្តល្អប្រពៃសម្រាប់ស្ថាប័នសិទ្ធិមនុស្សជាតិ ឯករាជ្យ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការឃ្លាំមើលការជួបប្រជុំ។

29 C.f. ACHPR, *Guidelines on Freedom of Association and Assembly in Africa*, para. 70 (a).
30 See also paragraph 52 below.
31 *Zhagiparov v. Kazakhstan* (CCPR/C/124/D/2441/2014), paras. 13.2–13.5. C.f. General Assembly resolution 53/1, annex.
32 CCPR/C/MRT/CO/1, para. 22. See also General Assembly resolution 66/164, OP 6.

៣១. រដ្ឋភាគីទាំងឡាយមានទំនួលខុសត្រូវចំបងសម្រាប់ការសម្រេចបាននូវសិទ្ធិនៃការជួបប្រជុំដោយសន្តិវិធី។ ទោះជាយ៉ាងនេះក៏ដោយ សហគ្រាសអាជីវកម្មមានទំនួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស រាប់ទាំង សិទ្ធិជួបជុំដោយសន្តិវិធី ឧទាហរណ៍ សហគមន៍ដែលរងផលប៉ះពាល់ពីសកម្មភាព និងនិយោជិករបស់សហគ្រាសទាំងនោះ។[33] អង្គភាពឯកជន និងសង្គមទាំមូលអាចត្រូវបានគេរំពឹងថា នឹងទទួលយកកម្រិតរំខានមួយចំនួន ដែលជាលទ្ធផលនៃការអនុវត្តសិទ្ធិ។

៣២. ដោយសារការជួប្រជុំដោយសន្តិវិធីច្រើនតែមានមុខងារបញ្ចេញមតិ ហើយសុន្ទរកថានយោបាយទទួលបានការការពារជាពិសេស ជាទម្រង់នៃការបញ្ចេញមតិ វាបង្ហាញថាការជួប្រជុំទាំងឡាយដែលមានសារនយោបាយគួរទទួលបានក្នុងកម្រិតមួយដែលអនុញ្ញាតទទួលឲ្យធ្វើបាន និងទទួលបានការការពារខ្ពស់។[34]

៣៣. មាត្រា ២១ និងសិទ្ធិពាក់ព័ន្ធមិនត្រឹមតែការពារអ្នកចូលរួមនៅខណៈពេល និងកន្លែងដែលការជួបប្រជុំកំពុងដំណើរការនោះទេ។ សកម្មភាពពាក់ព័ន្ធ ដែលបានធ្វើឡើងដោយ បុគ្គល ឬក្រុមមួយ ក្រៅពីបរិបទភ្លាមៗនៃការជួបប្រជុំគ្នា ប៉ុន្តែមានសារៈសំខាន់ដើម្បីធ្វើឲ្យការអនុវត្តនោះមានអត្ថន័យ ក៏ត្រូវបានគ្របដណ្តប់ផងដែរ។ ដូច្នេះ កាតព្វកិច្ចរបស់រដ្ឋភាគីទាំងនេះមានចំពោះសកម្មភាពទាំងឡាយ ដូចជា ការកៀរគររបស់អ្នកចូលរួម ឬអ្នករៀបចំ នូវធនធាន ការធ្វើផែនការការផ្សព្វផ្សាយព័ត៌មានអំពីព្រឹត្តិការណ៍ដែលនឹងមកដល់[35] ការរៀបចំសម្រាប់ការធ្វើដំណើរទៅកាន់កន្លែងជួបប្រជុំ[36] ការប្រាស្រ័យទាក់ទងរវាងអ្នកចូលរួមមុនពេល និងក្នុងពេលជួបប្រជុំ ការផ្សាយនៃ ឬពីការជួបប្រជុំ ហើយនិងការចាកចេញក្រោយពេលជួបប្រជុំ។ សកម្មភាពទាំងនេះអាចដូចជាការចូលរួមនៅក្នុងការជួបប្រជុំផ្ទាល់ ត្រូវមានការរឹតត្បិត ប៉ុន្តែសកម្មភាពទាំងនេះត្រូវតែមានប្រតិកម្មតបឲ្យបានល្អិតល្អន់។ តែទោះយ៉ាងណាក៏ដោយ ក៏គ្មាននរណាម្នាក់គួរត្រូវបានយាយី ឬប្រឈមមុខនឹងការសងសឹកផ្សេងទៀតដែលជាលទ្ធផលនៃវត្តមានរបស់ពួកគេនៅពេលចូលរួម ឬការភ្ជាប់ទំនាក់ទំនងទៅនឹងការជួបប្រជុំដោយសន្តិវិធីឡើយ។

៣៤. សកម្មភាពពាក់ព័ន្ធជាច្រើនកើតឡើងតាមអ៊ិនធឺណិត ឬតាមមធ្យបាយផ្សេងទៀតដែលពឹងលើសេវាកម្មឌីជីថល។ សកម្មភាពបែបនេះក៏ត្រូវបានការពារក្នុង មាត្រា ២១ ផងដែរ។ ឧទាហរណ៍ រដ្ឋឡាំងឡាយ មិនត្រូវធ្វើឲ្យរាំងស្ទះ ឬរារាំង ការភ្ជាប់អ៊ីធឺណិតទាក់ទងនឹងការជួបប្រជុំដោយសន្តិវិធីឡើយ។[37] ប្រការនេះអនុវត្តចំពោះការជ្រៀតជ្រែកតាមភូមិសាស្រ្ត ឬបច្ចេកវិទ្យាជាក់លាក់លើការតភ្ជាប់ ឬការចូលប្រើមាតិកា។ រដ្ឋទាំងឡាយគួរធានាថាសកម្មភាពរបស់អ្នកផ្តល់សេវាអ៊ិនធឺណិត និងអន្តរការី មិនត្រូវរឹតត្បិតការជួបប្រជុំ ឬឯកជនភាពរបស់អ្នកចូលរួមការជួបប្រជុំនោះឡើយ។

---

33 Guiding Principles on Business and Human Rights, A/HRC/17/31, annex.
34 General comment No. 34, paras. 34, 37–38 and 42–43. See also CCPR/C/LAO/CO/1, para. 33.
35 *Tulzhenkova v. Belarus* (CCPR/C/103/D/1838/2008), para. 9.3.
36 *Evrezov and others v. Belarus* (CCPR/C/112/D/1999/2010 and Corr.1), para. 8.5.
37 CCPR/C/CMR/CO/5, para. 41.

ការរឹតត្បិតណាមួយលើប្រតិបត្តិការនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវតែអនុលោមតាមការធ្វើតេស្ត សម្រាប់ការរឹតត្បិតលើសេរីភាពនៃការបញ្ចេញមតិ។[38]

៣៥. ទោះបីជាស្ថាប័នទាំងអស់របស់រដ្ឋមានកាតព្វកិច្ចគោរព និងធានាសិទ្ធិនៃការជួបប្រជុំដោយសន្តិវិធីក្តី ក៏សេចក្តីសម្រេចលើការជួបប្រជុំទាំងឡាយ ជារឿយៗ ត្រូវបានធ្វើឡើងនៅថ្នាក់មូលដ្ឋាន។ ដូច្នេះ រដ្ឋទាំងឡាយត្រូវធានាឲ្យមានការបណ្តុះបណ្តាល និងធនធានគ្រប់គ្រាន់សម្រាប់មន្ត្រីពាក់ព័ន្ធក្នុងការសម្រេចចិត្តទាំងនេះ នៅគ្រប់ថ្នាក់របស់រដ្ឋាភិបាល។

## IV. ការរឹតត្បិតសិទ្ធិខាងការប្រជុំដោយសន្តិវិធី

៣៦. ទោះជាសិទ្ធិនៃការជួបប្រជុំដោយសន្តិវិធីអាចក្នុងករណីខ្លះត្រូវបានកំណត់ក៏ដោយ ក៏ទំនួនខុសត្រូវ ឬភារកិច្ចនោះជារបស់អាជ្ញាធរក្នុងការធ្វើយុត្តិកម្មលើការរឹតត្បិតណាមួយដែរ។[39] អាជ្ញាធរត្រូវតែអាចបង្ហាញថា ការរឹតត្បិតណាមួយបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពស្របច្បាប់ ហើយលក្ខខណ្ឌនោះក៏ត្រូវតែចាំបាច់ និងសមាមាត្រ យ៉ាងហោចណាស់ក៏ត្រូវស្របតាមមូលដ្ឋានដែលអាចអនុញ្ញាតបានសម្រាប់ការរឹតត្បិតដែលមានចែងក្នុងមាត្រា ២១ ដូចដែលបានធ្វើការពិភាក្សាខាងក្រោម។ ប្រសិនបើទំនួនខុសត្រូវ ឬភារកិច្ចនោះមិនត្រូវបានបំពេញនោះទេ នេះរំលោភលើមាត្រា ២១ ហើយ។[40] ការដាក់កំហិតណាមួយគួរតែមានគោលបំណងសម្របសម្រួល សិទ្ធិ ជាជាងស្វែងរកការដាក់កម្រិតដែលមិនចាំបាច់ និងមិនសមាមាត្រ។[41] ការដាក់កម្រិតមិនត្រូវមានការរើសអើង ធ្វើឲ្យប៉ះពាល់ដល់ខ្លឹមសារនៃសិទ្ធិ ឬមានគោលបំណងរារាំងការចូលរួមក្នុងការជួបប្រជុំ ឬបង្កឲ្យមានផលប៉ះពាល់គួរឲ្យភ័យខ្លាចឡើយ។

៣៧. ការហាមឃាត់ការជួបប្រជុំជាក់លាក់មួយ អាចត្រូវបានគេចាត់ទុកជាវិធានការចុងក្រោយ។ ក្នុងករណីដែលការដាក់កំហិតលើការជួបប្រជុំ ត្រូវបានគេចាត់ទុកថាជារឿងចាំបាច់នោះ ដំបូងអាជ្ញាធរគួរតែរិះរកវិធីអនុវត្តវិធានការណ៍តិចតួចបំផុត។ រដ្ឋនានាគួរតែពិចារណាលើការអនុញ្ញាតឲ្យមានការប្រជុំមួយនិងធ្វើការសម្រេចចិត្តថាតើគួរតែមានវិធានការណ៍ទាក់ទងនឹងការរំលោភបំពានដែលអាចកើតមានក្នុងកំឡុងព្រឹត្តិការណ៍នេះដែរឬទេជាជាងដាក់កំហិតជាមុនក្នុងការប៉ុនប៉ងដើម្បីលុបបំបាត់ហានិភ័យទាំងអស់។[42]

៣៨. ការរឹតត្បិតណាមួយលើការចូលរួមក្នុងការជួបប្រជុំដោយសន្តិវិធី គួរតែផ្អែកលើការវាយតំលៃខុសៗគ្នា ឬជាលក្ខណៈបុគ្គល នៃការប្រព្រឹត្តរបស់អ្នកចូលរួម និងការជួបប្រជុំនោផ្ទាល់។ ការរឹតត្បិតដែលប៉ះពាល់ទាំងអស់លើការជួបប្រជុំដោយសន្តិវិធីគេអាចជឿថាមិនមានសមាមាត្រ។

[38] General comment No. 34, para. 34.
[39] *Gryb v. Belarus* (CCPR/C/108/D/1316/2004), para. 13.4.
[40] *Chebotareva v. Russian Federation* (CCPR/C/104/D/1866/2009), para. 9.3.
[41] *Turchenyak and others v. Belarus* (CCPR/C/108/D/1948/2010 and Corr.1), para. 7.4.
[42] C.f. OSCE & Venice Commission, *Guidelines on Freedom of Peaceful Assembly*, paras. 132, 220–22.

៣៩. ប្រយោគទី ២ នៃមាត្រា ២១ ចែងថា គ្មានការរឹតត្បិតណាមួយអាចត្រូវបានដាក់លើការអនុវត្តសិទ្ធិនេះ ក្រៅពីបទប្បញ្ញត្តិដែលអនុលោមតាមច្បាប់ឡើយ។ នេះបង្ហាញពីតម្រូវការជាផ្លូវការនៃនីត្យានុកូលកម្ម ដែលស្រដៀងនឹងតម្រូវការដែលការដាក់កម្រិតត្រូវតែ "មានចែងដោយច្បាប់" នៅក្នុងមាត្រាដទៃទៀតនៃកតិកាសញ្ញា។ ដូច្នេះ ការរឹតត្បិតត្រូវតែធ្វើឡើងតាមរយៈច្បាប់ ឬសេចក្តីសម្រេចរដ្ឋបាលដោយផ្អែកលើច្បាប់។ ច្បាប់ទាំងឡាយដែលមានបញ្ញាស្រពេចស្រពិលត្រូវតែមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីអនុញ្ញាតឲ្យសមាជិកសង្គមអាចសម្រេចចិត្តពីរបៀបគ្រប់គ្រងការប្រព្រឹត្តិរបស់ពួកគេ ហើយមិនអាចប្រគល់ឆន្ទានុសិទ្ធិដែលមិនមានដាក់កម្រិត និងមិនប៉ះពាល់លើអ្នកដែលត្រូវបានចោទប្រកាន់ពីបទអនុវត្តច្បាប់របស់ពួកគេឡើយ។[43]

៤០. មាត្រា ២១ ចែងថា ការរឹតត្បិតណាមួយត្រូវតែ "ចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ"។ ដូច្នេះ ការរឹតត្បិតទាំងឡាយត្រូវតែចាំបាច់ និងសមាមាត្រ នៅក្នុងបរិបទនៃសង្គម ដែលផ្អែកលើលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ ពហុនិយមនយោបាយ និងសិទ្ធិមនុស្ស ដែលផ្ទុយពីការគ្រាន់តែសមហេតុផល និងមានប្រយោជន៍តែមួយពេល។[44] ការរឹតត្បិតបែបនេះត្រូវតែជាការឆ្លើយតបសមស្របទៅនឹងតម្រូវការសង្គមដែលទាក់ទងទៅនឹងមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានទាំងឡាយដែលអាចអនុញ្ញាតបានក្នុងមាត្រា ២១។ ម្យ៉ាងវិញទៀត មូលដ្ឋានទាំងនោះត្រូវតែមានសមាមាត្រដែលទាមទារឲ្យមានការវាយតម្លៃតម្លៃ ថ្លឹងថ្លែងពីលក្ខណៈ និងផលប៉ះពាល់ដែលអាចបង្កអន្តរាយដល់ការជ្រៀតជ្រែកលើការអនុវត្តសិទ្ធិប្រឆាំងនឹងផលប្រយោជន៍ជាលទ្ធផលនៃមូលដ្ឋានមួយក្នុងចំណោមទាំងឡាយក្នុងការជ្រៀតជ្រែក។[45] ប្រសិនបើការធ្វើឲ្យខូចច្រើនជាងផលចំណេញ ការរឹតត្បិតគឺមិនសមាមាត្រ ហើយដូច្នេះមិនអាចអនុញ្ញាតឲ្យមានការរឹតត្បិតបានទេ។

៤១. ផ្នែកចុងក្រោយនៃប្រយោគទី ២ នៃមាត្រា ២១ ចែងអំពីមូលដ្ឋានស្របច្បាប់ដែលសិទ្ធិនៃការជួបជុំដោយសន្តិវិធីអាចត្រូវបានហាមឃាត់។ នេះគឺជាបញ្ជីដែលមានលក្ខណៈទូលំទូលាយដែលមានមូលដ្ឋានដូចតទៅ៖ ផលប្រយោជន៍សន្តិសុខជាតិ; សុវត្ថិភាពសាធារណៈ; សណ្តាប់ធ្នាប់សាធារណៈ; ការការពារសុខភាពសាធារណៈ ឬសីលធម៌; ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។

៤២. ផលប្រយោជន៍សន្តិសុខជាតិ "អាចជាមូលដ្ឋានសម្រាប់ការរឹតត្បិតទាំងឡាយ ប្រសិនការរឹតត្បិតបែបនោះចាំបាច់ដើម្បីរក្សាសមត្ថភាពរបស់រដ្ឋក្នុងការការពារអត្ថិភាពនៃប្រទេសជាតិ បូរណភាពទឹកដី ឬឯករាជ្យភាពនយោបាយប្រឆាំងនឹងការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង។[46] ត្រឹមកម្រិតនេះ វានឹងអាចធ្វើបានជាពិសេសក្នុងករណីមានការជួប

43 *Nepomnyashchiy v. Russian Federation* (CCPR/C/123/D/2318/2013), para. 7.7; and General comment No. 34, para. 25.

44 General comment No. 34, para. 34.

45 *Toregozhina v. Kazakhstan* (CCPR/C/112/D/2137/2012), para. 7.4.

46 Siracusa Principles on the Limitation and Derogation of Provisions in the International Covenant on Civil and Political Rights (E/CN.4/1985/4, annex), para. 29.

ប្រជុំដោយ "សន្តិវិធី" ប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ហេតុផលរឹងមាំដែលថាសន្តិសុខជាតិធ្វើឲ្យការរឹតត្បិតកាន់តែអាក្រក់នោះគឺ ការបង្ក្រាបសិទ្ធិមនុស្ស ការបង្ក្រាបនេះមិនអាចប្រើដើម្បីបង្ហាញការរឹតត្បិតបន្ថែមទៀតឡើយ រាប់ទាំង សិទ្ធិជួបប្រជុំដោយសន្តិវិធីផងដែរ។[47]

៤៣. ដើម្បីការពារ "សុវត្ថិភាពសារធារណៈ" ដែលត្រូវបានគេប្រើជាមូលដ្ឋានសម្រាប់ការរឹតត្បិតសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី[48] មូលដ្ឋាននោះត្រូវតែចែងថាការជួបប្រជុំបង្កើតនូវហានិភ័យពិត និងសំខាន់ចំពោះសុវត្ថិភាពរបស់មនុស្ស ចំពោះជីវិត) ឬសន្តិសុខរបស់មនុស្សឬ ( ហានិភ័យស្រដៀងគ្នានៃការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ។[49]

៤៤. "សណ្តាប់ធ្នាប់សារធារណៈ" សំដៅលើ ការបូកសរុបនៃវិធានទាំងឡាយដែលធានានូវដំណើរការល្អរបស់សង្គម ឬគោលការណ៍គ្រឹះដែលសង្គមត្រូវបានបង្កើតឡើង ដែលរួមមានទាំងការគោរពសិទ្ធិមនុស្ស រាប់ទាំងសិទ្ធិជួបប្រជុំដោយសន្តិវិធី។[50] រដ្ឋភាគីមិនគួរពឹងផ្អែកលើនិយមន័យមិនច្បាស់លាស់នៃពាក្យថា "សណ្តាប់ធ្នាប់សាធារណៈ" នេះ ដើម្បីលើកយកមូលហេតុមកបញ្ជាក់អំពីការរឹតត្បិតលើសិទ្ធិនៃការជួបជុំដោយសន្តិវិធីឡើយ។[51] ការជួបប្រជុំដោយសន្តិវិធីក្នុងករណីខ្លះអាចជាការរំខានជាស្រេច ឬដោយចេតនាទៅហើយ និងទាមទារឲ្យមានការអត់ធ្មត់ខ្ពស់។ "សណ្តាប់ធ្នាប់សាធារណៈនិង " ច្បាប់" និងសណ្តាប់ធ្នាប់មិនមែនជាសទិសន័យទេ " ហើយការហាមឃាត់ "ការមិនមានសណ្តាប់ធ្នាប់សាធារណៈនៅក្នុងច្បាប់ "ជាតិ មិនគួរត្រូវបានប្រើប្រាស់ដោយមិនត្រឹមត្រូវក្នុងការដាក់កម្រិតលើការជួបប្រជុំដោយសន្តិវិធីនោះទេ។

៤៥. ការការពារហេតុផល "សុខភាពសាធារណៈ" អាចអនុញ្ញាតឲ្យមានការរឹតត្បិតជាពិសេស ឧទាហរណ៍ នៅពេលមានការផ្ទុះឡើងនៃជំងឺឆ្លង និងការជួបប្រជុំនានាដែលប្រកបដោយគ្រោះថ្នាក់។ ក្នុងករណីនេះ អាចអនុវត្តបានផងដែរក្នុងករណីដែលស្ថានភាពអនាម័យក្នុងកំឡុងពេលជួបប្រជុំគ្នា បង្ហាញពីហានិភ័យយ៉ាងច្រើនដល់សុខភាពសាធារណជនទូទៅ ឬអ្នកចូលរួមផ្ទាល់។[52]

៤៦. ការរឹតត្បិតលើការជួបប្រជុំដោយសន្តិវិធី គួរតែត្រូវបានធ្វើឡើងជាពិសេសសម្រាប់ការការពារ ។"សីលធម៌" ប្រសិនបើត្រូវតែធ្វើឡើង ហេតុផលនោះមិនគួរត្រូវបានប្រើដើម្បីការពារការយល់ដឹងអំពីសីលធម៌ដែលទទួលបានតែពីប្រពៃណីជាលក្ខណៈសង្គម ទស្សន

---

[47] Ibid., para. 32.

[48] See CCPR/C/MKD/CO/3, para. 19; *Alekseev v. Russian Federation*, para. 9.5.

[49] Siracusa Principles, para. 33.

[50] Ibid., para. 22.

[51] CCPR/C/KAZ/CO/1, para. 26; CCPR/C/DZA/CO/4, para. 45.

[52] C.f. European Court of Human Rights, *Cisse v. France* (application No. 51346/99), judgment of 9 April 2002.

វិជ្ជា ឬសាសនា តែមួយមួយមុខនោះទេ[53] ហើយការរឹតត្បិតបែបនេះត្រូវតែយល់ច្បាស់ពីលក្ខណៈសកលនៃសិទ្ធិមនុស្ស ពហុនិយម និងគោលការណ៍មិនមានការរើសអើង។[54] ឧទាហរណ៍ ការរឹតត្បិតដោយផ្អែកលើមូលដ្ឋាននេះ អាចនឹងមិនត្រូវបានដាក់ដោយសារតែផ្ទុយនឹងការបង្ហាញពីទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ។[55]

៤៧. ការរឹតត្បិតធ្វើឡើងដើម្បីការពារ "សិទ្ធិ និងសេរីភាពរបស់អ្នកដទៃ" អាចទាក់ទងនឹងការការពារកតិការ ឬសិទ្ធិមនុស្សដទៃទៀតរបស់ប្រជាជន ដែលមិនបានចូលរួមក្នុងជួបប្រជុំ។ នៅពេលដំណាលគ្នានោះ ការជួបប្រជុំទាំងឡាយគឺជាការប្រើប្រាស់ស្របច្បាប់នូវទីសាធារណៈ និងកន្លែងផ្សេងទៀត ហើយដោយសារការជួបប្រជុំទាំងនោះអាចពាក់ព័ន្ធនឹងកម្រិតជាក់លាក់មួយនៃការការរំខានជាស្រេចរួចទៅហើយដល់ជីវិតធម្មតា ការរំខានបែបនេះត្រូវតែសម្រុះសម្រួលបាន លើកលែងតែ ការរំខានទាំងនោះដាក់បន្ទុកមិនសមាមាត្រ ដែលក្នុងនោះ អាជ្ញាធរត្រូវតែមានលទ្ធភាពផ្តល់យុត្តិកម្មលម្អិតសម្រាប់ការរឹតត្បិតណាមួយ។[56]

៤៨. បន្ថែមលើក្របខណ្ឌទូទៅសម្រាប់ការរឹតត្បឹតដែលមានចែងក្នុង មាត្រា ២១ ដូចដែលបានពិភាក្សាខាងលើ ការពិចារណាបន្ថែមមានពាក់ព័ន្ធនឹងការរឹតត្បិតសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី។ ចំណុចសំខាន់នៃការសម្រេចបាននូវសិទ្ធិគឺជាតម្រូវការដែលការរឹតត្បិតណាមួយ ជាគោលការណ៍ ត្រូវមានអព្យាក្រឹតភាព ហើយដូច្នេះ មិនទាក់ទងទៅនឹងសារដែលបានបង្ហាញដោយការជួបប្រជុំនោះទេ។[57] វិធីសាស្ត្រផ្ទុយពីនេះនឹងធ្វើឲ្យខូចខាតដល់គោលបំណងនៃការប្រជុំដោយសន្តិវិធី ដែលជាឧបករណ៍សក្តានុពលនៃការចូលរួមនយោបាយ និងសង្គម ដែលអនុញ្ញាតឲ្យប្រជាជនជំរុញគំនិត និងបង្កើតវិសាលភាពនៃការគាំទ្រដែលពួកគេទទួលបាន។

៤៩. វិធានដែលត្រូវអនុវត្តបានចំពោះសេរីភាពនៃការបញ្ចេញមតិ គួរតែត្រូវបានអនុវត្តនៅពេលដែលទាក់ទងនឹងធាតុនានានៃការជួបប្រជុំដែលមានសម្តែងចេញ។ ការរឹតត្បិតលើការជួប្រជុំដោយសន្តិវិធី មិនត្រូវយកមកប្រើ ដោយជាក់លាក់ ឬដោយប្រយោល ដើម្បីរារាំងការបញ្ចេញមតិប្រឆាំងខាងនយោបាយនឹងរដ្ឋាភិបាល[58]បញ្ហាប្រឈមចំពោះអាជ្ញាធររួមទាំង ការអំពាវនាវឱ្យមានការផ្លាស់ប្តូរប្រជាធិបតេយ្យរបស់រដ្ឋាភិបាល រដ្ឋធម្មនុញ្ញ ប្រព័ន្ធ

53 General comment No. 22, para. 8.
54 General comment No. 34, para. 32.
55 *Fedotova v. Russian Federation* (CCPR/C/106/D/1932/2010), paras. 10.5–10.6; *Alekseev v. Russian Federation*, para. 9.6.
56 *Stambrovsky v. Belarus* (CCPR/C/112/D/1987/2010), para. 7.6; *Pugach v. Belarus* (CCPR/C/114/D/1984/2010), para. 7.8.
57 *Alekseev v. Russian Federation*, para. 9.6.
58 CCPR/C/MDG/CO/4, para. 51.

នយោបាយ ឬការស្វះស្វែងរកស្វ័យសម្រេច។ ការរឹតត្បិតទាំងនោះ មិនគួរត្រូវបានប្រើ ដើម្បីហាមឃាត់ការប្រមាថកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់មន្ត្រី ឬស្ថាប័នរដ្ឋឡើយ។[59]

៥០. អនុលោមតាមមាត្រា ២០ នៃកតិកាសញ្ញា ការប្រជុំដោយសន្តិវិធីមិនអាចត្រូវបានប្រើសម្រាប់ការឃោសនាដើម្បីបង្កើតសង្គ្រាម (កថាខណ្ឌទី ១) ឬការតស៊ូមតិនៃការស្អប់ជាតិ ពូជសាសន៍ ឬសាសនា ដែលបង្កើតជាការញុះញង់ឱ្យមានការរើសអើង អរិភាពឬអំពើហិង្សា (កថាខណ្ឌទី ១)។[60] តាមដែលអាចធ្វើទៅបាន គួរតែចាត់វិធានការក្នុងករណីបែបនេះប្រឆាំងនឹងជនល្មើសម្នាក់ៗ ជាជាងប្រឆាំងនឹងការជួបប្រជុំទាំងមូល។ ការចូលរួមក្នុងការជួបប្រជុំដែលសារលេចធ្លោស្ថិតនៅក្នុងមាត្រា ២០ ត្រូវអនុលោមតាមតម្រូវការសម្រាប់ការរឹតត្បិតដោយមាត្រា ១៩ និង ២១។[61]

៥១. ជាទូទៅ ការប្រើប្រាស់ទង់ ឯកសណ្ឋាន សញ្ញា និងបដា ត្រូវចាត់ទុកជាទម្រង់នៃការបញ្ចេញមតិស្របច្បាប់ ដែលមិនគួរត្រូវបានរឹតត្បិតនោះទេ ទោះបីជានិមិត្តសញ្ញាបែបនេះជាការរំលឹកពីអតីតកាលដែលឈឺចាប់ក៏ដោយ។ ក្នុងករណីពិសេសដែលនិមិត្តសញ្ញាបែបនេះត្រូវបានផ្សារភ្ជាប់ដោយផ្ទាល់ និងភាគច្រើន ទាក់ទងនឹងការញុះញង់ឱ្យមានការរើសអើង អរិភាព ឬអំពើហឹង្សា ការរឹតត្បិតសមស្របគួរតែត្រូវបានអនុវត្ត។[62]

៥២. ការពិតដែលថា ការជួបប្រជុំកង្កឲ្យមានកំហឹង ឬបង្កឱ្យមានប្រតិកម្មអរិភាព ពីសមាជិកសាធារណៈ ប្រឆាំងនឹងអ្នកចូលរួម ដែលជាវិធានទូទៅ មិនបង្ហាញហេតុផលអំពីការរឹតត្បិតឡើយ ការជួបប្រជុំត្រូវតែអនុញ្ញាតិឲ្យធ្វើទៅបាន ហើយអ្នកចូលរួមក្នុងការជួបប្រជុំនេះត្រូវតែទទួលបានការការពារ។ [63] ទោះយ៉ាងណាក៏ដោយ ក្នុងករណីពិសេសដែលរដ្ឋមិនអាចការពារអ្នកចូលរួមពីការគំរាមកំហែងធ្ងន់ធ្ងរដល់សុវត្ថិភាពរបស់ពួកគេ អាចនឹងមានការរឹតត្បិតលើការចូលរួមការជួបប្រជុំ។ ការរឹតត្បិតបែបនេះ ត្រូវតែអាចទប់ទល់នឹងការត្រួតពិនិត្យយ៉ាងតឹងរឹង។ ហានិភ័យនៃអំពើហឹង្សាដែលមិនបានបញ្ជាក់ច្បាស់លាស់ ឬគ្រាន់ជាលទ្ធភាពដែលអាជ្ញាធរនឹងមិនមានលទ្ធភាពក្នុងការការពារ ឬបញ្ឈប់មិនឲ្យមាន

59 CCPR/C/79/Add. 86, para. 18; General comment No. 34, para. 38.

60 Article 20 (1) and (2).

61 See General comment No. 34, paras. 50–52; article 4, Convention on the Elimination of Racial Discrimination; and Committee on the Elimination of Racial Discrimination, General recommendation No. 35. See also the Rabat Plan of Action (2012), A/HRC/22/17/Add.4, appendix, para. 29 as well as the Beirut Declaration and its 18 commitments on “Faith for Rights” (A/HRC/40/58, annexes I and II).

62 C.f. OSCE & Venice Commission, *Guidelines on Freedom of Peaceful Assembly*, para. 152. See also European Court of Human Rights, *Fáber v. Hungary* (application No. 40721/08), judgment of 24 October 2012, paras. 56–58.

63 *Alekseev v. Russian Federation*, para. 9.6. See also paragraph 18 above.

អំពើហឹង្សាដែលចេញពីអ្នកដែលប្រឆាំងនឹងការជួបប្រជុំ គឺមិនទាន់គ្រប់គ្រាន់នោះទេ រដ្ឋត្រូវតែមានលទ្ធភាពបង្ហាញ ដោយផ្អែកលើការវាយតម្លៃហានិភ័យជាក់ស្តែងថាខ្លួននឹងមិនអាចទប់ស្កាត់ស្ថានការណ៍បានទេ ទោះបីជាសមត្ថភាពអនុវត្តច្បាប់សំខាន់ៗត្រូវបានដាក់ពង្រាយក៏ដោយ។[64] ការរឹតត្បិតតិចជាងមុន ដូចជា ការពន្យារពេល ឬការផ្លាស់ប្តូរទីតាំងនៃការជួបប្រជុំត្រូវតែយកមកពិចារណាមុនពេលធ្វើការហាមឃាត់។

៥៣. បទបញ្ញត្តិអំពីពេលវេលា ទីកន្លែង និងចរឹត នៃការប្រមូលផ្តុំជាទូទៅមានលក្ខណៈអព្យាក្រិត ហើយក្នុងខណៈដែលមានវិសាលភាពខ្លះសំរាប់ការរឹតត្បឹតដែលតម្រូវអោយមានការធ្វើអោយត្រឹមត្រូវតាមច្បាប់នូវធាតុផ្សំទាំងនេះ នោះវាជាភារកិច្ចរបស់អាជ្ញាធរដែលត្រូវបកស្រាយពន្យល់អំពីការរឹតត្បឹតដែលបានដាក់ចេញផ្អែកលើករណីនិមួយៗ។[65] ការរឹតត្បឹតនោះគួរតែបង្កលក្ខណៈដែលអាចអោយអ្នកចូលរួមទាំងឡាយជួបប្រជុំ/ប្រមូលផ្តុំក្នុងរង្វង់ចំងាយសមរម្យអាចមើលឃើញស្តាប់ឮដោយក្រុមគោលដៅ និងទីកន្លែងណាក៏ដោយអោយតែមានសារៈសំខាន់ចំពោះគោលបំណងរបស់ពួកគេ។[66]

៥៤. ពាក់ពន្ធ័ការរឹតត្បឹតចំពោះពេលវេលានៃការប្រមូលផ្តុំនានា អ្នកចូលរួមត្រូវតែមានឱកាសគ្រប់គ្រាន់ដើម្បីសម្តែងមតិឬទាមទារនូវគោលបំណងរបស់ពួកគេដោយប្រសិទ្ធិភាព។[67] ការជួបប្រជុំដោយសន្តិវិធីជាទូទៅត្រូវបានទុកអោយចប់/បញ្ចប់ដោយខ្លួនឯង។ ការរឹតត្បឹតពាក់ពន្ធ័ពេលវេលានិងកាលបរិច្ឆេទជាក់លាក់ថាតើពេលណាដែលការជួបជុំអាចធ្វើបានឬធ្វើមិនបាន វាបង្កអោយមានកង្វល់អំពីភាពសម្រុះសម្រួល/ភាពបត់បែនបានជាមួយនិងកតិកាសញ្ញា។[68] ការជួបជុំមិនគួរត្រូវបានកំហិតដោយសារតែវាបានកើតឡើងញឹកញាប់ហើយនោះទេ។ ពេលវេលា ថេរវេលា ឬភាពញឹកញាប់នៃបាតុកម្មមួយប្រហែលអាចដើរតួរគន្លិះក្នុងការសម្រេចបានគោលបំណងនៃការប្រមូលផ្តុំនោះ។ ទោះយ៉ាងណាក៏ដោយផលប៉ះពាល់បន្ថែមចំពោះការជួបប្រជុំច្រើនលើកច្រើនសារអាចត្រូវបានថ្លឹងថ្លែងនូវការវាយតម្លៃអំពីភាពសមមាត្រនៃការរឹតត្បឹត។ ឧទាហរណ៍ការប្រមូលផ្តុំមួយចំនួនតែងតែធ្វើឡើងទៀងទាត់នៅពេលយប់ក្នុងតំបន់លំនៅដ្ឋានដែលអាចជះផលប៉ះពាល់ដល់ការរស់នៅរបស់អ្នកជិតខាងទាំងឡាយនោះ។

៥៥. ពាក់ពន្ធ័ការរឹតត្បឹតចំពោះទីកន្លែង ជាគោលការណ៍បាតុកម្មដោយសន្តិវិធីប្រហែលអាចប្រារព្ធធ្វើបាននៅគ្រប់ទីលាននានាដែលសាធារណជនអាច/គួរមានសិទ្ធិចេញចូលបានដូចជាទីលានសាធារណៈ ឬផ្លូវសាធារណៈ។[69] ខណៈដែលវិធានពាក់ពន្ធ័សិទ្ធិចេញចូលរបស់សាធារណជនចំពោះទីតាំងមួយចំនួនដូចជាអាគារ សួនសាធារណៈ ប្រហែលអាចត្រូវបានកំរិតផងដែរចំពោះសិទ្ធិប្រមូលផ្តុំក្នុងទីកន្លែងទាំងនោះ ដូចនេះការរឹតត្បឹតសិទ្ធិជួបជុំត្រូវតែអនុវត្តផ្អែកលើយុត្តិសំអាងហេតុអនុលោមតាមមាត្រា

[64] *Alekseev v. Russian Federation*, para. 9.6.
[65] C.f. OSCE & គណកម្មការVenice, គោលការណ៍ណែនាំអំពីសេរីភាពជួបប្រជុំប្រមូលផ្តុំដោយសន្តិវិធី, កឋាខណ្ឌ 132.
[66] *Turchenyak et al. v. Belarus*, កឋាខណ្ឌ 7.4.
[67] C.f. តុលាការអ៊ឺរ៉ុបដើម្បីសិទ្ធិមនុស្ស, *Éva Molnár v. Hungary* (សេចក្តីសម្រេចលេខ 10346/05), សាលក្រមចុះថ្ងៃទី 7 តុលា 2008, កឋាខណ្ឌ 42.
[68] គណកម្មការសិទ្ធិមនុស្ស CCPR/C/KOR/CO/4, កឋាខណ្ឌ 52; CCPR/C/TJK/CO/3, កឋាខណ្ឌ 49.
[69] C.f. គណកម្មាធិការអន្តរអាមេរិកាំងដើម្បីសិទ្ធិមនុស្ស, បាតុកម្មនិងសិទ្ធិមនុស្ស កឋាខណ្ឌ 72.

៥៥។ ការជួបប្រជុំដោយសន្តិវិធីមិនគួរត្រូវបានរុញអោយទៅធ្វើនៅទីតាំងដាច់ស្រយ៉ាលដែលបាតុកម្មនោះមិនអាចទាក់ទាញចំណាប់អារម្មណ៍របស់សមត្ថកិច្ចដែលមានភារកិច្ចដោះស្រាយនិងសាធារណជនឡើយ។[70] ជាគោលការណ៍ទូទៅការហាមឃាត់រាល់ការជួបប្រជុំនៅទីកន្លែងនានាក្នុងទីក្រុង[71] ដូចជាទីតាំងសាធារណៈ លើកលែងតែទីកន្លែងជាក់លាក់ណាមួយទោះស្ថិតក្នុងទីក្រុង[72] ឬក្រៅបេះដូងនៃទីក្រុង[73] ឬការហាមឃាត់ចំពោះការជួបប្រជុំនានាតាមបណ្តាផ្លូវក្នុងទីក្រុង មិនគួរត្រូវបានដាក់កំហិតឡើយ។

៥៦. ការកំណត់ជាបរិវេណហាមឃាត់ដូចជាតុលាការ រដ្ឋសភា ទីតាំងមានសារសំខាន់ផ្នែកប្រវត្តិសាស្ត្រឬអាគារសាធារណៈដទៃទៀតដែលមិនគួរ មានការប្រមូលផ្តុំ ជាទូទៅគួរជៀសវាងកុំកំណត់ ព្រោះកន្លែងទាំងនោះជាទីសាធារណៈស្រេចហើយ។ ប្រសិនជាកំណត់ថាការជួបជុំនៅក្នុងនិងនៅជុំវិញនៃទីកន្លែងទាំងនោះត្រូវបានកំហិត ការហាមឃាត់នេះត្រូវតែមានយុត្តិសំអាងហេតុជាក់លាក់និងកំណត់ព្រំដែនយ៉ាងចង្អៀត/ល្អិតល្អន់។[74]

៥៧. ខណៈដែលការប្រមូលផ្តុំក្នុងទីតាំងឯកជនក៏ស្ថិតក្នុងបរិបទនៃសិទ្ធិប្រមូលផ្តុំដោយសន្តិវិធី[75] ផលប្រយោជន៍របស់អ្នកដទៃដែលមានសិទ្ធិលើទ្រព្យសម្បត្តិទាំងនោះត្រូវបានយកមកថ្លឹងថ្លែងពិចារណា។ សំណួរសួរថាតើការហាមឃាត់ប្រភេទណាដែលអាចអនុវត្តបានលើការជួបជុំនោះអាស្រ័យលើការពិចារណាថាតើទីតាំងនោះធ្លាប់ត្រូវបានចេញចូលញឹកញាប់និងសាធារណៈកំរិតណា ចរិតនៃការបំពានលើសិទ្ធិរបស់ម្ចាស់ទីតាំង ថាតើម្ចាស់ទីតាំងយល់ព្រមអោយប្រើប្រាស់ ថាតើសិទ្ធិលើកម្មសិទ្ធិកំពុងមានវិវាទដោយសារការជួបប្រជុំ ហើយថាតើអ្នកចូលរួមទាំងឡាយមានមធ្យោបាយសមហេតុផលផ្សេងទៀតដើម្បីសម្រេចគោលបំណងនៃការជួបប្រជុំនោះដែរទេ តាមគោលការណ៍អាចមើលឃើញស្តាប់ឮ[76] ។ សិទ្ធិប្រើប្រាស់ទីតាំងឯកជនមិនគួរត្រូវបានបដិសេធព្រោះតែការរើសអើងឡើយ។

៥៨. ចំពោះកង្វល់ការហាមឃាត់ពាក់ពន្ធ័ចរិតនៃការជួបប្រជុំដោយសន្តិវិធី អ្នកចូលរួមមានសេរីភាពកំណត់ថាតើពួកគេចង់ប្រើឧបករណ៍អ្វី ដូចជាផ្ទាំងបដា ឬប្រដាប់បំពងសម្លេង ឬឧបករណ៍ភ្លេង ឬមធ្យោបាយបច្ចេកទេសដទៃទៀតដូចជាឧបករណ៍បញ្ចាំងស្លៃជាដើម។ ការជួបប្រជុំខ្លះតម្រូវអោយមានការតម្លើងជាគ្រោងតង់ជាសំណង់បណ្តោះអាសន្នរួមមានប្រពន្ធ័សម្លេងដើម្បីអោយឮដល់ក្រុមគោលដៅ និងសម្រេចបាននូវគោលបំណងនៃការជួបប្រជុំទាមទារទាំងនោះ។[77]

៥៩. ជាទូទៅរដ្ឋភាគីទាំងឡាយមិនត្រូវកំណត់ចំនួនអ្នកចូលរួមការជួបជុំប្រមូលផ្តុំឡើយ។[78] ការកំរិតចំនួនអ្នកចូលរួមអាចធ្វើទៅបានល្គឹកណាតែមានសំអាងហេតុស្របច្បាប់សំរាប់ការរឹតត្បឹតទាំងនោះ

[70] គណកម្មការសិទ្ធិមនុស្ស CCPR/C/KOR/CO/4,កឋាខណ្ឌ 52; CCPR/C/KAZ/CO/1,កឋាខណ្ឌ 26.
[71] គណកម្មការសិទ្ធិមនុស្ស CCPR/C/DZA/CO/4, កឋាខណ្ឌ 45.
[72] *Turchenyak et al. v. Belarus*, កឋាខណ្ឌ 7.5.
[73] *Sudalenko v. Belarus* (គណកម្មការសិទ្ធិមនុស្ស CCPR/C/113/D/1992/2010), កឋាខណ្ឌ 8.5.
[74] *Zündel v. Canada* (គណកម្មការសិទ្ធិមនុស្ស CCPR/C/78/D/953/2000), កឋាខណ្ឌ 8.5.
[75] C.f. *Giménez v. Paraguay* (គណកម្មការសិទ្ធិមនុស្ស CCPR/C/123/D/2372/2014), កឋាខណ្ឌ 8.3; តុលាការអឺរ៉ុបដើម្បីសិទ្ធិមនុស្ស, *Annenkov* និងអ្នកដទៃ *v. Russia* (សេចក្តីសម្រេចលេខ 31475/10), សាលក្រមចុះថ្ងៃទី 25 កក្កដា 2017, កឋាខណ្ឌ 122.
[76] C.f. តុលាការអឺរ៉ុបដើម្បីសិទ្ធិមនុស្ស, *Appleby and others v. United Kingdom* (សេចក្តីសម្រេចលេខ 44306/98), សាលក្រមចុះថ្ងៃទី 6 ឧសភា 2003, កឋាខណ្ឌ 47.
[77] មើល *Frumkin v. Russia*, កឋាខណ្ឌ107.
[78] គណកម្មការសិទ្ធិមនុស្ស CCPR/C/THA/CO/2, កឋាខណ្ឌ 39.

ហើយមានចែងក្នុងមាត្រា២១ ឧទាហរណ៍ពាក់ពន្ធ័យ៉ាងខ្លាំងចំពោះសុវត្ថភាពសាធារណៈដូចជាចំណុះ/ទម្ងន់ផ្ទុកនៃពហុកីឡាដ្ឋាន ស្ពាន ឬមូលហេតុនៃភ័យន្តរាយផ្នែកសុខភាពសាធារណៈ ដូចជាគំលាតសង្គម។

៦០. ការពាក់របាំងមុខឬម៉ាសរបស់អ្នកចូលរួមធ្វើបាតុកម្មក្នុងន័យលាក់អត្តសញ្ញាណ រក្សាឯកជនភាពកុំអោយមានការកត់ចំណាំដៅទុក សងសឹក ព្រោះថាសម័យទំនើបនេះមានឧបករណ៍ឈ្លបយកការណ៍មានប្រសិទ្ធិភាពណាស់ គឺត្រូវបានចាត់ជាសម្ភារៈសម្តែងមតិក្នុងបាតុកម្មដោយសន្តិវិធី។ ភាពអនាមិករបស់អ្នកចូលរួមគួរត្រូវបានអនុញ្ញាត លើកលែងតែការប្រព្រឹត្តរបស់បុគ្គលជាក់លាក់នោះមានសំអាងហេតុពិតប្រាកដដែលអាចចាប់ខ្លួនបាន[79] ឬមានហេតុផលយ៉ាងច្បាស់លាស់ដទៃទៀត។[80] ការប្រើប្រាស់របាំងមុខបិទបាំងអត្តសញ្ញាណមិនគួរចាត់ជាសញ្ញាទុច្ចរិតហិង្សាឡើយ។

៦១. ក្នុងខណៈការប្រមូលពត៌មាននិងទិន្នន័យពាក់ពន្ធ័ដោយអាជ្ញាធរមានសមត្ថកិច្ចអាចក្នុងកាលទេសជាក់លាក់ជួយដល់កិច្ចសម្របសម្រួលការជួបប្រជុំខ្លះ នេះមិនត្រូវក្លាយជាការបង្ក្រាបលើសិទ្ធិឬបង្កើតអោយមានឥទ្ធិពលអាក្រក់ឡើយ។ ការប្រមូលពត៌មានដោយស្ថាប័នសាធារណៈឬឯកជនក៏ដោយតាមរយៈមធ្យោបាយឈ្លបយកការណ៍លើការទំនាក់ទំនងឬតាមវិធីប្រមូល ចែកចាយ ជ្រៀតចូលរក្សាទុកទិន្នន័យត្រូវតែអនុវត្តអនុលោមតាមបទដ្ឋានច្បាប់អន្តរជាតិជាធរមានផ្អែកលើសិទ្ធិឯកជនភាពបុគ្គល ហើយមិនត្រូវប្រើក្នុងគោលបំណងគំរាមគំហែងដល់អ្នកចូលរួមឬអ្នកត្រៀមនឹងចូលរួមបាតុកម្មឡើយ។[81] ការអនុវត្តរបៀបនេះគួរត្រូវបានធ្វើនីយត្តកម្មផ្អែកលើច្បាប់ជាតិនិងច្បាប់អន្តរជាតិជាធរមាននិងត្រូវមានការត្រួតពិនិត្យដោយអំណាចតុលាការ។[82]

៦២. មិនមែនថាអោយតែការជួបប្រជុំក្នុងទីសាធារណៈ សិទ្ធិឯកជនភាពរបស់បុគ្គលមិនអាចត្រូវបានបំពាននោះទេ។ សិទ្ធិនេះប្រហែលអាចបំពានបាន ឧទាហរណ៍ដោយវិធី/មធ្យោបាយសំគាល់ផ្ទៃមុខឬក៏ដោយបច្ចេកវិទ្យាផ្សេងៗដែលអាចកំណត់អត្តសញ្ញាណបុគ្គលក្នុងហ្វូងមនុស្ស។[83] វាត្រូវបានអនុវត្តដូចគ្នាចំពោះការឃ្លាំមើលបណ្តាញសារពត៌មានសង្គមដើម្បីប្រមូលពត៌មានអំពីការចូលរួមបាតុកម្មដោយសន្តិវិធី។ ការត្រួតពិនិត្យដោយឯករាជ្យនិងតម្លាភាពនិងការឃ្លាំមើលត្រូវតែអនុវត្តសេចក្តីសម្រេចចិត្តពាក់ពន្ធ័ការប្រមូលពត៌មាន ទិន្នន័យផ្ទាល់ខ្លួនបុគ្គលដែលចូលរួមបាតុកម្មដោយសន្តិវិធី និងការចែករំលែក រក្សាទុកពត៌មាន ទិន្នន័យទាំងនោះ ជាមួយនិងទស្សនៈក្នុងការធានាចំពោះសកម្មភាពទាំងនោះអោយអនុលោមនិងកតិកាសញ្ញា។

៦៣. សេរីភាពរបស់មន្ត្រីសាធារណៈក្នុងការចូលរួមបាតុកម្មដោយសន្តិវិធីមិនត្រូវបានកំរិតលើសពីសេចក្តីត្រូវការក្នុងការធានាជំនឿទុកចិត្តពីសាធារណជន ភាពមិនលំអៀង សមត្ថភាពក្នុងការប្រតិបត្តិតួរ

79 C.f. OSCE & គណកម្មាធិការVenice គោលការណ៍ណែនាំអំពីបាតុកម្មដោយសន្តិវិធី, កឋាខណ្ឌ153; គណកម្មាធិការអាហ្វ្រិចដើម្បីសិទ្ធិមនុស្ស ACHPR, គោលការណ៍ណែនាំអំពីសេរីភាពសមាគមនិងការជួបជុំប្រមូលផ្តុំក្នុងទ្វីបអាហ្វ្រិច កឋាខណ្ឌ 81.

80 ការគោរពរបាំងមុខជាអត្តសញ្ញណ, មើល កឋាខណ្ឌ51 ខាងលើ។

81 ក្រុមប្រឹក្សាសិទ្ធិមនុស្ស A/ HRC/31/66, កឋាខណ្ឌ73.

82 គណៈកម្មការសិទ្ធិមនុស្ស CCPR/C/KOR/CO/4, កឋាខណ្ឌ 42–43.

83 C.f. A/HRC/44/24, កឋាខណ្ឌ 33–34.

នាទីភារកិច្ចនៃវិជ្ជាជីវៈផ្តល់សេវារបស់ពួកគេឡើយ[84] ហើយរាល់ការកំហិតទាំងនោះត្រូវតែអនុលោមតាមមាត្រា២១។

៦៤. ការតម្រូវអោយអ្នកចូលរួមឬអ្នករៀបចំ ទោះជាការចាត់ចែងឬក៏ចូលរួមជាថវិកាជួយដល់កិច្ចការសណ្តាប់ធ្នាប់សន្តិសុខ[85] ជំនួយផ្នែកពេទ្យឬកិច្ចការសំអាតអនាម័យ[86] ឬសេវាសាធារណៈដទៃទៀតដែលពាក់ពន្ធ័និងការប្រមូលផ្តុំដោយសន្តិវិធី ជាទូទៅគឺត្រូវបានចាត់ទុកថាជាទង្វើមិនអនុលោមតាមមាត្រា២១។[87]

៦៥. អ្នករៀបចំនិងអ្នកចូលរួមត្រូវបានសង្ឃឹមថាអនុវត្តតាមគោលការណ៍ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ហើយនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់លើបទល្មើសដែលខ្លួនបានប្រព្រឹត្តិ រួមមានបទញុះញង់អ្នកដទៃ[88] បើសិនក្នុងកាលទេសពិសេសដែលថាអ្នករៀបចំបាតុកម្មមិនទទួលខុសត្រូវផ្ទាល់ចំពោះអំពើបណ្តាលអោយមានការខូចខាត់និងរងរបួសទេ រាល់ការកសាងសំណុំរឿងប្រឆាំងនិងគាត់អាចទៅរួចល្គឹកណាតែមានភស្តុតាងសមហេតុផលបញ្ជាក់ថាគាត់បានឃើញបានដឹងនិងមានលទ្ធភាពអាចការពារទប់ស្កាត់ទង្វើល្មើសទាំងនោះបាន។[89] ជាការអនុវត្តល្អដែរប្រសិនណាអ្នករៀបចំបាតុកម្មចាត់ចែងអោយមានបុគ្គលិក/ភ្នាក់ងារសន្តិសុខក្នុងជួរបាតុករធ្វើកិច្ចការសណ្តាប់ធ្នាប់ដោយខ្លួនឯង ប៉ុន្តែវាពុំមែនជាអ្វីដែលច្បាប់តម្រូវនោះទេ។

៦៦. អាជ្ញាធរមិនត្រូវទាមទារការសន្យា/ធ្វើកិច្ចសន្យាពីអ្នកចូលរួមឬអ្នករៀបចំថានឹងមិនចូលរួមឬមិនរៀបចំការជួបប្រជុំនានានៅថ្ងៃអនាគតឡើយ។[90] ផ្ទុយទៅវិញ គ្មានបុគ្គលណាដែលត្រូវបានគេបង្ខំអោយចូលរួមបាតុកម្ម/ការប្រមូលផ្តុំឡើយ។[91]

៦៧. ពេលណាទោសបញ្ញតិផ្នែកព្រហ្មទណ្ឌឬផ្នែករដ្ឋប្បវេណីត្រូវបានដាក់អោយទទួលខុសត្រូវដល់អ្នករៀបចំឬអ្នកចូលរួមបាតុកម្ម ចំពោះបទល្មើសដែលគេបានប្រព្រឹត្តិ ទណ្ឌកម្មនោះត្រូវតែសមមាត្រគ្មានការរើសអើងហើយមិនផ្អែកលើការចោទប្រកាន់ ការបកស្រាយបទល្មើសបែបប្រហែលព្រាវៗមិនច្បាស់លាស់ឡើយ អ្វីៗត្រូវតែអនុលោមតាមកតិកាសញ្ញា។

៦៨. ខណៈដែលអំពើភេរវកម្មត្រូវចាត់ជាបទល្មើសព្រហ្មទណ្ឌអនុលោមតាមច្បាប់អន្តរជាតិ និយមន័យនៃបទល្មើសនេះមិនត្រូវអោយទូលាយពេកឬបង្កប់ភាពរើសអើង ហើយមិនត្រូវអនុវត្តរបៀបរឹតបន្តឹងបន្ទច់បង្អាក់ដល់ការអនុវត្តសិទ្ធិធ្វើបាតុកម្មដោយសន្តិវិធីឡើយ[92] បើគ្រាន់តែការចូលរួម និងរៀបចំការ

[84] C.f. OSCE & គណកម្មាធិការVenice គោលការណ៍ណែនាំអំពីបាតុកម្មដោយសន្តិវិធី, កឋាខណ្ឌ 110.
[85] គណកម្មការសិទ្ធិមនុស្ស CCPR/C/CHE/CO/4, កឋាខណ្ឌ 48.
[86] *Poliakov v. Belarus* (CCPR/C/111/D/2030/2011), កឋាខណ្ឌ 8.2–8.3; CCPR/C/BLR/CO/5, កឋាខណ្ឌ 51 (a).
[87] C.f. គណកម្មាធិការអាហ្វ្រិចដើម្បីសិទ្ធិមនុស្ស ACHPR, គោលការណ៍ណែនាំអំពីសេរីភាពសមាគមនិងការជួបជុំប្រមូលផ្តុំក្នុងទ្វីបអាហ្វ្រិច កឋាខណ្ឌ102 (b).
[88] ក្រុមប្រឹក្សាសិទ្ធិមនុស្ស A/HRC/31/66, កឋាខណ្ឌ26
[89] C.f. OSCE & គណកម្មាធិការVenice គោលការណ៍ណែនាំអំពីបាតុកម្មដោយសន្តិវិធី កឋាខណ្ឌ 224.
[90] គណកម្មការសិទ្ធិមនុស្ស CCPR/C/KHM/CO/2,កឋាខណ្ឌ 22; CCPR/C/JOR/CO/5, កឋាខណ្ឌ 32.
[91] CCPR/C/TKM/CO/2, កឋាខណ្ឌ 44.
[92] CCPR/C/SWZ/CO/1, កឋាខណ្ឌ 36; CCPR/C/BHR/CO/1, កឋាខណ្ឌ 29. មើលផងដែរ ក្រុមប្រឹក្សាសិទ្ធិមនុស្ស A/HRC/40/52.

ប្រមូលផ្តុំដោយសន្តិវិធីមិនត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ/ឧក្រិដ្ឋក្រោមច្បាប់ប្រឆាំងអំពើភេវរកម្មឡើយ។

៦៩. បណ្តឹងទៅតុលាការឬសាលាជំរះក្តីដទៃទៀតដើម្បីស្វែងរកដំណោះស្រាយចំពោះការរឹតត្បឹតនោះត្រូវតែអាចធ្វើបានរួមមានលទ្ធភាពប្តឹងឧទ្ធរណ៍និងប្តឹងសើរើ។ ភាពទាន់ពេលវេលានិងរយៈពេលនៃកិច្ចនីតិវិធីប្រឆាំងការរឹតត្បឹតចំពោះការជួបប្រជុំ មិនត្រូវក្លាយជាការបំពានដល់ការអនុវត្តសិទ្ធិឡើយ។[93] កិច្ចធានាការពារផ្នែកនីតិវិធីមានចែងក្នុងកតិកាសញ្ញាត្រូវអនុវត្តលើគ្រប់ករណីទាំងអស់ រួមមានការឃុំខ្លួន ការដាក់ទណ្ឌកម្មផ្នែកផាកពិន័យដែលពាក់ពន្ធ័និងបាតុកម្មដោយសន្តិវិធី។[94]

## V. របបស្តីពីការជូនដំណឹង

៧០. ការតម្រូវអោយសុំច្បាប់អនុញ្ញាតពីអាជ្ញាធរ វាបំពានទស្សនៈដែលថាការជួបប្រជុំដោយសន្តិវិធីជាសិទ្ធិសារវន្តរបស់មនុស្ស។[95] ប្រពន្ធ័នៃការជូនដំណឹងតម្រូវថាបុគ្គលដែលចង់រៀបចំបាតុកម្មដោយសន្តិវិធីត្រូវតែជូនដំណឹងអោយអាជ្ញាធរដឹងជាមុននូវព័ត៌មានសំខាន់ៗមួយចំនួនដែលចាំបាច់អាចជម្រាបបានដើម្បីអាជ្ញាធរអាចមានលទ្ធភាពសម្របសម្រួលបាតុកម្មដោយសន្តិវិធីប្រព្រឹត្តទៅដោយរលូននិងអាចការពារសិទ្ធិមនុស្សរបស់អ្នកដទៃផង។[96] ក្នុងពេលជាមួយគ្នាដែរ ការតម្រូវនេះមិនត្រូវប្រើដោយបំពានលើសិទ្ធិជួបជុំប្រមូលផ្តុំដោយសន្តិវិធីឡើយ ហើយរាល់ការជ្រៀតជ្រែករឹតត្បឹតពីអាជ្ញាធរត្រូវតែមានយុត្តិសំអាងហេតុអនុលោមតាមមាត្រា២១។[97] ការអនុវត្តរបបជូនដំណឹងមិនត្រូវក្លាយជាលេសរារាំងការជួបប្រជុំដោយសន្តិវិធីទេ។[98] នីតិវិធីជូនដំណឹងត្រូវតែមានតម្លាភាពមិនការិយាធិបតេយ្យពេកទេ[99] ការទាមទារទាំងឡាយចំពោះអ្នករៀបចំបាតុកម្មត្រូវតែសមមាត្រទៅនិងឥទ្ធិពលសាធារណៈដែលមានសក្តានុពល នៃការជួបជុំប្រមូលផ្តុំនោះ និងមិនត្រូវបង់ថ្លៃសេវាឡើយ។

៧១. ការខកខានជូនដំណឹងដល់អាជ្ញាធរចំពោះការជួបជុំប្រមូលផ្តុំដែលច្បាប់ប្រទេសមួយតម្រូវ មិនមែនជាលេសត្រូវចាត់ទុកការចូលរួមបាតុកម្មជាទង្វើខុសច្បាប់ឡើយ ហើយក៏មិនត្រូវប្រើជាលេសបំបែកបាតុកម្មដែរ ឬធ្វើការចាប់ខ្លួនអ្នកចូលរួម អ្នករៀបចំ ឬដាក់ទណ្ឌកម្មដែលមិនទំនងដូចជាចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ កន្លែងណាដែលទណ្ឌកម្មផ្នែករដ្ឋបាលតម្រូវអោយអ្នករៀបចំទទួលខុសត្រូវចំពោះមុខច្បាប់ពាក់ពន្ធ័ការមិនបានជូនដំណឹង អាជ្ញាធរត្រូវតែមានយុត្តិសំអាងហេតុច្បាស់លាស់។[100] ការខកខានមិនបានជូនដំណឹងមិនមែនជាលេសដោះសាររបស់អាជ្ញាធរចំពោះការមិនអនុវត្តតួរ

93 CCPR/C/POL/CO/6 កឋាខណ្ឌ 23.

94 *E.V. v. Belarus* (CCPR/C/112/D/1989/2010), កឋាខណ្ឌ 6.6.

95 គណកម្មការសិទ្ធិមនុស្ស CCPR/C/MAR/CO/6, កឋាខណ្ឌ 45; CCPR/C/GMB/CO/2, កឋាខណ្ឌ 41; និង គណកម្មាធិការអាហ្វ្រិចដើម្បីសិទ្ធិមនុស្ស ACHPR, គោលការណ៍ណែនាំអំពីសេរីភាពសមាគមនិងការជួបជុំប្រមូលផ្តុំក្នុងទ្វីបអាហ្វ្រិច កឋាខណ្ឌ 71.

96 *Kivenmaa v. Finland*, កឋាខណ្ឌ 9.2. មើលផងដែរ គណកម្មាធិការអាហ្វ្រិចដើម្បីសិទ្ធិមនុស្ស ACHPR, គោលការណ៍ណែនាំអំពីសេរីភាពសមាគមនិងការជួបជុំប្រមូលផ្តុំក្នុងទ្វីបអាហ្វ្រិច កឋាខណ្ឌ 72.

97 Ibid. មើលផងដែរ *Sekerko v. Belarus*, កឋាខណ្ឌ9.4.

98 *Popova v. Russian Federation*, កឋាខណ្ឌ7.5.

99 *Poliakov v. Belarus*, កឋាខណ្ឌ 8.3.

100 See, e.g., *Popova v. Russian Federation*, para. 7.4, 7.5. មើលផងដែរ ក្រុមប្រឹក្សាសិទ្ធិមនុស្សA/HRC/31/66, កឋាខណ្ឌ 23.

នាទីកាតព្វកិច្ចក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីសម្របសម្រួលការជួបជុំប្រមូលផ្តុំ និងដើម្បីការពារសន្តិសុខសណ្តាប់ធ្នាប់បាតុកម្មឡើយ។

៧២. ការតម្រូវអោយជូនដំណឹងដល់អាជ្ញាធរជាមុនចំពោះការជួបជុំប្រមូលផ្តុំនានាត្រូវតែមានចែងក្នុងច្បាប់ជាតិ។ ថេរវេលាអប្បបរិមានៃការជូនដំណឹងជាមុនអាចខុសគ្នាពីប្រទេសមួយទៅប្រទេសមួយផ្អែកលើបរិបទនិងកំរិតតម្រូវការនូវកិច្ចសម្របសម្រួល ប៉ុន្តែមិនត្រូវយូរពេកឡើយ។[101] បើសិនមានការរឹតត្បឹតបន្ទាប់ពីបានជូនដំណឹងជាមុនហើយ ការហាមឃាត់នោះត្រូវតែផ្តល់ព័ត៌មានអោយទាន់ពេលវេលាគ្រប់គ្រាន់ដើម្បីទុកសិទ្ធិប្តឹងតវ៉ាទៅតុលាការឬយន្តការដំណោះស្រាយដទៃទៀត។ របបជូនដំណឹងមិនគួរផាត់ចេញការជួបជុំប្រមូលផ្តុំណាដែលប្រមើលឃើញថាជះផលប៉ះពាល់តិចតួចដល់អ្នកដទៃ ឧទាហរណ៍ ដោយសារតែចរិតលក្ខណៈ ទីតាំង ទំហំ និងពេលវេលានៃការជួបជុំប្រមូលផ្តុំនោះមានកំរិត។ របបជូនដំណឹងមិនគួរអនុវត្តចំពោះការជួបជុំប្រមូលផ្តុំដែលកើតឡើងជាបន្តបន្ទាប់នោះទេ ព្រោះថាវាគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីជូនដំណឹងជាមុនឡើយ។[102]

៧៣. ប្រទេសណាដែលរបបអនុញ្ញាតមានចែងក្នុងច្បាប់ជាតិ គេត្រូវតែអនុវត្តជាលក្ខណៈប្រពន្ធ័ជូនដំណឹងដោយការអនុញ្ញាតនោះត្រូវតែផ្តល់ជូនដោយស្វ័យប្រវត្តិដោយពុំយកលេសដែលមិនសមហេតុផលមករារាំងឡើយ។ ហើយរបបជូនដំណឹងក៏មិនត្រូវបំភ្លៃការអនុវត្តទៅជារបបសុំការអនុញ្ញាតដែរ។[103]

## VI. ភារកិច្ចនិងអំណាចមន្ត្រីប្រតិបត្តិច្បាប់

៧៤. មន្ត្រីប្រតិបត្តិច្បាប់ដែលធ្វើកិច្ចការប្រនគរបាលលើការជួបជុំប្រមូលផ្តុំត្រូវគោរពនិងធានាសិទ្ធិជាសារវន្តរបស់អ្នករៀបចំនិងអ្នកចូលរួមធ្វើបាតុកម្ម ក្នុងកំឡុងពេលនោះមន្ត្រីប្រតិបត្តិច្បាប់ក៏ការពារផងដែរដល់អ្នកយកពត៌មាន[104] អ្នកឃ្លាំមើលនិងអ្នកសង្កេតការណ៍ បុគ្គលិកសុខាភិបាលនិងសាធារណជនដទៃទៀតព្រមទាំងការពារទ្រព្យសម្បត្តិឯកជននិងសាធារណៈពីការបង្កហានិភ័យទាំងឡាយ។[105] វិធីសាស្ត្រសំខាន់ជាសារវន្តរបស់អាជ្ញាធរគឺចូលទៅសម្របសម្រួលបាតុកម្មដោយសន្តិវិធី បើសិនជា ចាំបាច់។

៧៥. ស្ថាប័នប្រតិបត្តិច្បាប់ពាក់ពន្ធ័ បើសិនជាអាចធ្វើបាន គួរតែបង្កើត/បង្កលក្ខណៈងាយស្រួលនិងសម្រួលដល់ការទំនាក់ទំនងកិច្ចសន្ទនារវាងភាគីពាក់ពន្ធ័ក្នុងបាតុកម្ម រយៈពេលមុន ក្នុងកំឡុងពេលកំពុងធ្វើបាតុកម្មសំដៅលើកស្ទួយរបៀបរៀបរយ កាត់បន្ថយភាពតានតឹងនិងដោះស្រាយបញ្ហា/ វិវាទ។[106] ខណៈដែលនេះជាការអនុវត្តល្អសំរាប់អ្នករៀបចំនិងអ្នកចូលរួមគួរតែប្រតិបត្តិ ក៏វាមិនមែនបង្ខំអោយត្រូវតែធ្វើអញ្ចឹងដែរ។

---

[101] គណកម្មការសិទ្ធិមនុស្ស CCPR/CO/83/KEN, កឋាខណ្ឌ 23; CCPR/C/CHE/CO/4,កឋាខណ្ឌ 48; CCPR/C/DZA/CO/4, កឋាខណ្ឌ 45.

[102] *Popova v. Russian Federation*, កឋាខណ្ឌ 7.5. មើលផងដែរ តុលាការអឺរ៉ុបដើម្បីសិទ្ធិមនុស្ស *Éva Molnár v. Hungary*, កឋាខណ្ឌ 38.

[103] CCPR/C/UZB/CO/5, កឋាខណ្ឌ 46–47; CCPR/C/JOR/CO/5, កឋាខណ្ឌ 32.

[104] CCPR/C/AGO/CO/1,កឋាខណ្ឌ 21; CCPR/C/GEO/CO/4,កឋាខណ្ឌ 12; និង CCPR/C/KOR/CO/4, កឋាខណ្ឌ 52.

[105] ក្រុមប្រឹក្សាសិទ្ធិមនុស្ស A/HRC/31/66, កឋាខណ្ឌ 41.

[106] Ibid., កឋាខណ្ឌ 38.

៧៦. កន្លែងណាដែលវត្តមានរបស់មន្រ្តីប្រតិបត្តិច្បាប់ចាំបាច់ត្រូវតែមាន កិច្ចប្រតិបត្តិការនគរបាលលើការជួបជុំប្រមូលផ្តុំនោះ គួរត្រូវបានរៀបចំជាផែនការអនុវត្តជាមួយគោលបំណងបង្កលក្ខណៈសម្រួលអោយបាតុកម្មប្រព្រឹត្តទៅតាមការគ្រោងទុកនិងដោយរលូន ដែលអាចកាត់បន្ថយជាអតិបរមានូវហានិភ័យដែលមានសក្តានុពលដូចជាបណ្តាលអោយមានអ្នករងរបួសនិងការខូចខាតទ្រព្យសម្បត្តិ។[107] ផែនការនោះត្រូវដាក់ចេញសេចក្តីណែនាំជាក់លាក់ច្បាស់លាស់ លំអិតអំពីសម្ភារៈឧបករណ៍ និងការដាក់ពង្រាយកំលាំងព្រមទាំងអង្គភាពចូលរួម។

៧៧. ផែនការសំរាប់ភាពអាសន្នតាមប្រភេទនិងកម្មវិធីហ្វឹកហ្វឺនកំលាំងគួរពន្យល់ច្បាស់លាស់ដោយស្ថាប័នប្រតិបត្តិច្បាប់ពាក់ពន្ធ័នានា ដោយចំពោះគឺអំពីកិច្ចការរបនគរបាលគ្រប់គ្រងបាតុកម្មដែលគ្មានការជូនដំណឹងដល់អាជ្ញាធរជាមុនដែលវាប្រហែលអាចប៉ះពាល់ដល់សណ្តាប់សាធារណៈ។[108] ត្រូវមានរចនាសម្ពន្ធ័បញ្ជាច្បាស់លាស់ភ្ជាប់ជាមួយនូវការទទួលខុសត្រូវ ព្រមទាំងចែងអំពីទម្រង់ការនៃការថតរូប/ថតសម្លេង និងការកត់ត្រាព្រឹត្តិការណ៍ជាលាយលក្ខអក្សរ ហើយធានាថារាល់មន្ត្រី/កងកំលាំងមានអត្តសញ្ញាណច្បាស់លាស់ និងត្រូវធ្វើរបាយការណ៍រាល់ការប្រើប្រាស់កំលាំង។

៧៨. មន្ត្រីប្រតិបត្តិច្បាប់គួរស្វែងរកការបន្ធូរបន្ថយស្ថានការណ៍ដែលអាចបង្កអោយមានអំពើហិង្សា។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវព្យាយាមប្រើប្រាស់មធ្យោបាយអហិង្សាអោយអស់លទ្ធភាព ហើយត្រូវផ្តល់ការព្រមានច្បាស់ៗបើសិនជាដល់ពេលចាំបាច់បំផុតនៃការប្រើប្រាស់កំលាំងជាជំរើសចុងក្រោយ ពីព្រោះតែមធ្យោបាយអហិង្សាដែលបានប្រើគឺពុំមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងសភាពការណ៍។ រាល់ការប្រើប្រាស់កំលាំងដាច់ខាតត្រូវអនុលោមតាមគោលការណ៍ជាសារវន្តគឺ ភាពស្របច្បាប់ ភាពចាំបាច់ សមមាត្រ ការប្រុងប្រយត្ន័អត់ធ្មត់ខ្ពស់ និងគ្មានការរើសអើងដែលមានចែងក្នុងមាត្រា៦ និងមាត្រា៧នៃកតិកាសញ្ញា ហើយមន្ត្រីដែលពាក់ពន្ធ័ការប្រើប្រាស់កំលាំងត្រូវភ្ជាប់ជាមួយការទទួលខុសត្រូវចំពោះមុខច្បាប់បើសិនមានការបំពានគោលការណ៍និងក្រមសីលធម៌ស្តីពីការប្រើប្រាស់កំលាំង។[109] របបគតិយុត្តិជាតិស្តីអំពីការប្រើប្រាស់កំលាំងដោយមន្ត្រីប្រតិបត្តិច្បាប់ត្រូវតែអនុលោមតាមបទដ្ឋានគតិយុត្តិអន្តរជាតិមានចែងក្នុងគោលការណ៍ជាមូលដ្ឋានស្តីអំពីការប្រើកំលាំងនិងអាវុធរបស់មន្ត្រីប្រតិបត្តិច្បាប់និងសេចក្តីណែនាំសិទ្ធិមនុស្សអង្គការសហប្រជាជាតិស្តីអំពីការប្រើអាវុធមិនប្រល័យក្នុងកិច្ចប្រតិបត្តិច្បាប់។[110]

៧៩. មានតែកំរិតអប្បបរិមានៃកំលាំងដែលចាំបាច់ប៉ុណ្ណោះប្រហែលអាចប្រើបានក្នុងគោលដៅប្រតិបត្តិការបេសកម្មស្របច្បាប់ក្នុងកំឡុងពេលគ្រប់គ្រងបាតុកម្ម។ នៅពេលដែលភាពចាំបាច់នៃការប្រើកំលាំងត្រូវបានបញ្ចប់ខណៈដែលការចាប់ខ្លួនជនបង្កហិង្សាបានសម្រេចដោយសុវត្ថភាព នោះការប្រើប្រាស់កំលាំងបន្ត គឺមិនអនុញ្ញាតឡើយ។[111] មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវប្រើកំលាំងលើសលប់/គ្មានសមមាត្រក្នុងកាលទេសគ្រាន់តែបំបែកបាតុកម្ម បង្ការការប្រព្រឹត្តបទល្មើស ឬដើម្បីចាប់ខ្លួនជនបង្ក ជន

107 ក្រុមប្រឹក្សាសិទ្ធិមនុស្ស សេចក្តីសម្រេចលេខ38/11, បុព្វកថា កឋាខណ្ឌ 10; A/HRC/26/36, កឋាខណ្ឌ 51.
108 A/HRC/31/66, កឋាខណ្ឌ 37.
109 មើលអនុសាសន៍ទូទៅលេខ 36, កឋាខណ្ឌ13–14.
110 មើលផងដែរ ក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់
111 Ibid., មាត្រា3.

សង្ស័យដែលពុំមានការគំរាមគំហែងកំរិតខ្ពស់ឡើយ។[112] ច្បាប់ជាតិមិនត្រូវផ្តល់អំណាចទូលាយពេក ដល់មន្ត្រីប្រតិបត្តិច្បាប់ ឧទាហរណ៍រាល់ការប្រើកំលាំងសុទ្ធតែចាំបាច់បំផុតទាំងអស់ ដើម្បីបំបែកគ្រប់ទំរង់នៃបាតុកម្ម ដូចជាថាពាក្យសាមញ្ញៗ គឺអាចបាញ់បំបាក់ជើង។ ជាពិសេសច្បាប់ជាតិមិនត្រូវអនុញ្ញាត អោយមានការប្រើកំលាំងប្រឆាំងអ្នកចូលរួមក្នុងបាតុកម្មដោយផ្អែកលើអារម្មណ៍មួរម៉ៅខាងភេទ ភាពហួសប្រមាណ និងការរើសអើងនានាឡើយ។[113]

៨០. មានតែមន្ត្រីប្រតិបត្តិច្បាប់ ដែលបានទទួលការបណ្តុះបណ្តាលក្នុងការរក្សាសណ្តាប់ធ្នាប់នៃការជួបជុំ ព្រមទាំងស្តង់ដារសិទ្ធិមនុស្សដែលពាក់ព័ន្ធប៉ុណ្ណោះទេ ដែលគួរតែត្រូវបានគេដាក់ពង្រាយសម្រាប់គោលបំណងនេះ ។[114] ការបណ្តុះបណ្តាលគួរតែបញ្ជ្រៀបមន្ត្រីទាំងនោះអំពីតម្រូវការជាក់លាក់របស់បុគ្គល ឬ ក្រុមក្នុងស្ថានភាពងាយរងគ្រោះ ដែលក្នុងករណីខ្លះ ជារួមមានស្ត្រី កុមារ ឬ ជនពិការដែលបានចូលរួមក្នុងការជួបជុំគ្នាដោយសន្តិវិធី។ យោធាមិនគួរត្រូវបានគេប្រើសម្រាប់រក្សាសណ្តាប់ធ្នាប់ក្នុងការជួបជុំគ្នាទេ[115] ក៏ប៉ុន្តែប្រសិនបើនៅក្នុងកាលៈទេសៈពិសេស និង ផ្អែកលើមូលដ្ឋានបណ្តោះអាសន្ន ដែលពួកគេត្រូវបានដាក់ពង្រាយក្នុងការគាំទ្រ ពួកគេត្រូវតែទទួលបាននូវការបណ្តុះបណ្តាលផ្នែកសិទ្ធិមនុស្សសមស្រប ហើយត្រូវតែគោរពតាមវិធាន និង បទដ្ឋានអន្តរជាតិដូចគ្នានឹងមន្ត្រីប្រតិបត្តិច្បាប់ដែរ។[116]

៨១. មន្ត្រីប្រតិបត្តិច្បាប់ទាំងអស់ដែលទទួលខុសត្រូវក្នុងការរក្សាសណ្តាប់ធ្នាប់នៃការជួបជុំត្រូវតែបំពាក់ឲ្យបានសមរម្យ រួមទាំងក្នុងករណីចាំបាច់ត្រូវបំពាក់ជាមួយនឹងអាវុធដែលមិនងាយនឹងបង្កគ្រោះថ្នាក់ដល់ជីវិត និងឧបករណ៍ការពារ ដែលសមស្រប និងតាមបទដ្ឋាន។ រដ្ឋភាគីទាំងអស់ត្រូវធានាថា រាល់អាវុធទាំងអស់ រួមទាំងអាវុធដែលមិនងាយបង្កគ្រោះថ្នាក់ដល់ជីវិត គឺត្រូវស្ថិតក្រោមការធ្វើតេស្តឯករាជ្យតឹងរឹង ធានាថាមន្ត្រីដែលបានដាក់ពង្រាយរួមជាមួយនឹងអាវុធទាំងនោះទទួលបានការបណ្តុះបណ្តាលជាក់លាក់ និង វាយតម្លៃ និង តាមដានផលប៉ះពាល់របស់ពួកគេ ចំពោះសិទ្ធិរបស់អ្នកដែលរងផលប៉ះពាល់ទាំងនោះ។[117] ភ្នាក់ងារប្រតិបត្តិច្បាប់ត្រូវតែប្រុងប្រយ័ត្ន ចំពោះផលប៉ះពាល់នៃការរើសអើងជាសក្តានុពល នៃយុទ្ធសាស្ត្ររក្សាសណ្តាប់ធ្នាប់ជាក់លាក់ រួមទាំងបរិបទនៃបច្ចេកវិទ្យាថ្មី និងការលើកឡើងជាដំណោះស្រាយចំពោះបញ្ហាទាំងនេះ។[118]

112 Ibid., អត្ថាធិប្បាយចំពោះ មាត្រា3.
113 គណកម្មការសិទ្ធិមនុស្ស CCPR/C/MAR/CO/6, កថាខណ្ឌ45–46; CCPR/C/BHR/CO/1, កថាខណ្ឌ 55.
114 CCPR/C/KHM/CO/2, para. 12; CCPR/C/GRC/CO/2, para. 42; and CCPR/C/BGR/CO/4, para. 38.
115 CCPR/C/VEN/CO/4, para. 14; and ACHPR, *Guidelines on Policing Assemblies in Africa*, para. 3.2.
116 Code of Conduct for Law Enforcement Officials, art. 1.

117 General comment No.36, para. 14. See also UN Human Rights Guidance on Less-Lethal Weapons in Law Enforcement, section 4; and Basic Principles on the Use of Force and Firearms by Law Enforcement Officials, principle 2.
118 CCPR/C/GBR/CO/7, para. 11; A/HRC/44/24, para. 32.

៨២. ការបង្ការការឃុំខ្លួនមនុស្សដោយការកំណត់គោលដៅ ដើម្បីរារាំងពួកគេពីការចូលរួមក្នុងការជួបជុំគ្នា អាចជាការដកហូតសិទ្ធិសេរីភាពតាមទំនើងចិត្ត ដែលមិនស្របតាមសិទ្ធិនៃការជួបជុំដោយសន្តិវិធីទេ។[119] នេះជាករណីពិសេស កាលណាការឃុំខ្លួនមានរយៈពេលច្រើនជាងពីរបីម៉ោង។ ក្នុងករណីដែលច្បាប់ក្នុងស្រុកអនុញ្ញាតឲ្យមានការឃុំឃាំងបែបនេះ វាអាចត្រូវបានប្រើបានតែក្នុងករណីពិសេសបំផុតប៉ុណ្ណោះ[120] គឺសម្រាប់រយៈពេលមិនយូរជាងរយៈពេលចាំបាច់បំផុតនោះទេ ហើយក៏ក្នុងករណីដែលអាជ្ញាធរមានភ័ស្តុតាងបញ្ជាក់ពីចេតនារបស់បុគ្គល ដែលពាក់ព័ន្ធក្នុងការចូលរួម ឬ ញុះញង់ឲ្យមានអំពើហិង្សា ក្នុងពេលជួបជុំពិសេសមួយ ព្រមទាំងក្នុងករណីណា ដែលវិធានការផ្សេងៗទៀតដើម្បីបង្ការការកើតមានឡើងនៃអំពើហិង្សានឹងប្រាកដជាមិនមានលក្ខណៈគ្រប់គ្រាន់ទេ។[121] ការអនុវត្តនៃការចាប់ខ្លួនទ្រង់ទ្រាយធំដោយមិនរើសមុខ មុនពេល ក្នុងអំឡុងពេល ឬបន្ទាប់ពីការជួបជុំគឺមានលក្ខណៈតាមទំនើងចិត្ត ហើយមិនស្របច្បាប់ទាល់តែសោះ។[122]

៨៣. អំណាចនៃ" ឃាត់ និង ឆែកឆេរ" ឬ" ឃាត់ខ្លួនជនសង្ស័យដោយគ្មានការបំពាន" ដែលអនុវត្តចំពោះអ្នកទាំងឡាយណាដែលចូលរួមក្នុងការជួបជុំគ្នា ឬ មានបំណងនឹងទៅចូលរួម ត្រូវតែអនុវត្តដោយផ្អែកលើការសង្ស័យសមហេតុផលរបស់គណៈកម្មការ ឬ ការគំរាមកំហែងអំពីបទល្មើសធ្ងន់ធ្ងរណាមួយ ហើយត្រូវតែមិនត្រូវបានប្រើក្នុងលក្ខណៈរើសអើងឡើយ។[123] ការពិតដែលថាអាជ្ញាធរភ្ជាប់បុគ្គលណាម្នាក់ជាមួយការជួបជុំដោយសន្តិវិធីគឺមិនបង្កើតបានជាមូលដ្ឋានសមហេតុផល សម្រាប់ការឃាត់ខ្លួន និង ឆែកឆេរពួកគេនោះទេ។[124]

៨៤. ការបង្ខាំងមនុស្ស ដែលមន្ត្រីប្រតិបត្តិច្បាប់បានឡោមព័ទ្ធ និង បិទ នៅត្រង់កន្លែងដែលមានអ្នកចូលរួម អាចត្រូវបានប្រើបានតែក្នុងករណីដែលចាំបាច់ និង សមាមាត្រដើម្បីអាចធ្វើដូចនេះបាន ដើម្បីជាដំណោះស្រាយទៅនឹងអំពើហិង្សាជាក់ស្តែង ឬ ការគំរាមកំហែងដែលនឹងកើតឡើងពីកន្លែងនោះប៉ុណ្ណោះ។ វិធានការអនុវត្តច្បាប់ចាំបាច់ដែលផ្តោតលើបុគ្គលជាក់លាក់ច្រើនតែជាជំរើសក្នុងការបង្ខាំងមនុស្ស។ ការយកចិត្តទុកដក់ជាពិសេសត្រូវតែធ្វើឡើងឲ្យបានច្រើនតាមអាចធ្វើទៅបាន ដើម្បីបង្ខាំងមនុស្សណាម្នាក់លុះត្រាតែបុគ្គលនោះជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអំពើហិង្សា ព្រមទាំងត្រូវ

119 CCPR/C/MKD/CO/3, para. 19.
120 General comment No. 35, para. 15.
121 C.f. European Court of Human Rights, *S., V. and A. v. Denmark* (application Nos. 35553/12, 36678/12 and 36711/12), judgment of 22 October 2018 (Grand Chamber), paras. 77 and 127.
122 CCPR/C/CAN/CO/6, para. 15.
123 CCPR/C/GBR/CO/7, para. 11; CCPR/C/USA/CO/4, para. 7.
124 A/HRC/31/66, para. 43.

កំណត់នូវថេរវេលានៃការបង្ខាំងមនុស្សជាអប្បបរមាតាមដែលចាំបាច់។ ក្នុងករណីដែលការបង្ខាំងមនុស្សត្រូវបានប្រើប្រាស់ដោយមិនរើសអើង ឬ ធ្ងន់ធ្ងរ វារំលោភលើសិទ្ធិនៃការជួបជុំដោយសន្តិវិធី ហើយក៏អាចរំលោភសិទ្ធិផ្សេងទៀតដូចជាសិទ្ធិមានសេរីភាពរួចផុតពីការឃុំខ្លួនតាមទំនើងចិត្ត និង សេរីភាពក្នុងការធ្វើដំណើរ។[125]

៨៥. មានតែករណីពិសេសប៉ុណ្ណោះទេ ដែលការជួបជុំអាចត្រូវបានគេបំបែក។ ការបំបែកអាចត្រូវបានគេធ្វើឡើង ប្រសិនបើការជួបជុំបែបនោះលែងប្រកបដោយសន្តិវិធីទៀត ហើយ ឬ ប្រសិនបើមានភ័ស្តុតាងច្បាស់លាស់ថា មានការគំរាមកំហែងដែលនឹងកើតមានឡើងនូវអំពើហិង្សាធ្ងន់ធ្ងរ ដែលមិនអាចត្រូវបានដោះស្រាយដោយវិធានការសមាមាត្រផ្សេងទៀតបាន ដូចជាការចាប់ខ្លួនដោយមានគោលដៅ ប៉ុន្តែគ្រប់ករណីទាំងអស់ វិធានប្រតិបត្តិច្បាប់ស្តីពីការប្រើប្រាស់កម្លាំងត្រូវតែត្រូវបានអនុវត្តតាមយ៉ាងតឹងរឹង។ល័ក្ខខ័ណ្ឌនៃការចេញបទបញ្ជាឲ្យមានការបំបែកនៃការជួបជុំគួរតែត្រូវបានកំណត់ដោយច្បាប់ក្នុងស្រុក ហើយមានតែមន្ត្រីដែលមានការអនុញ្ញាតត្រឹមត្រូវទេ ដែលអាចចេញបទបញ្ជាឲ្យមានការបំបែកការជួបជុំដោយសន្តិវិធី។ ការជួបប្រជុំគ្នាដែលនៅតែប្រព្រឹត្តទៅដោយសន្តិវិធី ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ វាបណ្តាលឲ្យមានការរំខានកម្រិតខ្ពស់ ដូចជាការរាំងស្ទះចរាចរណ៍រយៈពេលយូរក៏អាចត្រូវបានគេបំបែកដែរ តាមច្បាប់គឺថា កាលណាការរំខាននេះមានលក្ខណៈ "ធ្ងន់ធ្ងរ និង នៅតែបន្ត"។[126]

៨៦. ក្នុងករណីដែលសេចក្តីសម្រេចចិត្ត ដើម្បីបំបែកត្រូវបានអនុវត្ត ដោយស្របតាមច្បាប់ជាតិ និង អន្តរជាតិ ការប្រើប្រាស់កម្លាំងគួរតែត្រូវជៀសវាង។ ក្នុងករណីដែលមិនអាចធ្វើទៅបានក្នុងកាលៈទេសៈណាមួយ មានតែកម្លាំងអប្បបរមាចាំបាច់ប៉ុណ្ណោះដែលអាចត្រូវបានគេប្រើប្រាស់។[127] តាមដែលអាចធ្វើទៅបាន កំលាំងណាមួយដែលបានប្រើគួរតែត្រូវធ្វើឡើងប្រឆាំងនឹងបុគ្គល ឬ ក្រុមជាក់លាក់ដែលចូលរួមក្នុង ឬ គំរាមកំហែងឲ្យមានអំពើហិង្សាតែប៉ុណ្ណោះ។ ការប្រើប្រាស់កម្លាំងទំនងជាអាចបណ្តាលឲ្យមានការរងរបួសដោយសារធ្វេសប្រហែសច្រើនជាងមិនគួរត្រូវបានប្រើប្រឆាំងនឹងបុគ្គល ឬ ក្រុមណាមួយដែលកំពុងតស៊ូដោយអកម្មនោះឡើយ។[128]

៨៧. អាវុធដែលមិនងាយនឹងបង្កគ្រោះថ្នាក់ដល់ជីវិតអាចរងផលប៉ះពាល់ដល់តំបន់ណាមួយ ដូចជាហ្គាសបង្ហូរទឹកភ្នែក និង កាណុងបាញ់ទឹក ដែលបណ្តាលឲ្យទទួលរងនូវផល

125 C.f. European Court of Human Rights, *Austin and others* v. *United Kingdom* (application Nos. 39629/09, 40713/09; and 41008/09), judgment of 15 March 2012 (Grand Chamber), para. 68.
126 A/HRC/31/66, para. 62.
127 Basic Principles on the Use of Force and Firearms by Law Enforcement Officials, principle 13; A/HRC/26/36, para. 75.
128 UN Human Rights Guidance on Less-Lethal Weapons in Law Enforcement, para. 2.10.

ប៉ះពាល់ដោយមិនរើសមុខ។ នៅពេលដែលអាវុធទាំងនេះត្រូវបានប្រើ រាល់កិច្ចខិតខំសមហេតុផលនានាគួរតែត្រូវបានអនុវត្ត ដើម្បីកំណត់ហានិភ័យនានា ដូចជាការបង្កឲ្យមានការរត់ជាន់គ្នា ឬ បង្កគ្រោះថ្នាក់ដល់អ្នកឈររមើល។ អាវុធទាំងនេះគួរតែត្រូវបានប្រើជាវិធានការចុងក្រោយ បន្ទាប់ពីការព្រមានដោយផ្ទាល់មាត់ ហើយមានឱកាសគ្រប់គ្រាន់ដែលត្រូវផ្ដល់ឲ្យអ្នកចូលរួមក្នុងការជួបជុំបំបែកពីគ្នា។ ឧស្ម័នបង្ហូរទឹកភ្នែកមិនគួរត្រូវបានប្រើក្នុងកន្លែងបង្ខាំងឡើយ។[129]

៨៨. អាវុធមិនមែនជាឧបករណ៍សមស្របសម្រាប់ការរក្សាសណ្ដាប់ធ្នាប់សាធារណៈអំឡុងពេលនៃការជួបជុំគ្នាទេ[130] ហើយជាទូទៅមិនត្រូវបានប្រើវា ដើម្បីបំបែកការជួបជុំគ្នាឡើយ។[131] ដើម្បីអនុវត្តតាមច្បាប់អន្តរជាតិ រាល់ការប្រើប្រាស់អាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ក្នុងបរិបទនៃការជួបជុំគ្នាត្រូវមានកំហិតចំពោះបុគ្គលណាដែលគេបានកំណត់គោលដៅហើយ ក្នុងកាលៈទេសៈណាដែលចាំបាច់យ៉ាងខ្លាំងត្រូវប្រឈមនឹងការគំរាមកំហែងភ្លាមៗដល់អាយុជីវិត ឬ ការរងរបួសធ្ងន់ធ្ងរ។[132] ដោយសារតែមានការគំរាមកំហែង អាវុធបែបនេះអាចធ្វើឲ្យគ្រោះថ្នាក់ដល់អាយុជីវិត កម្រិតអប្បបរមានេះក៏គួរតែត្រូវបានអនុវត្តផងដែរ ចំពោះការបាញ់គ្រាប់កាំភ្លើងដែកដែលស្រោបជ័រកៅស៊ូ។[133] កាលណាមន្ត្រីប្រតិបត្តិច្បាប់ត្រៀមលក្ខណៈក្នុងការប្រើប្រាស់កម្លាំង ឬអំពើហិង្សាត្រូវបានគេចាត់ទុកថាទំនងជាកើតមានឡើង អាជ្ញាធរត្រូវតែធានាឲ្យមានកន្លែងផ្ដល់សេវាវេជ្ជសាស្ត្រឲ្យបានគ្រប់គ្រាន់ផងដែរ។ វាមិនដែលស្របច្បាប់នោះទេ កាលណាមានការបាញ់ដោយមិនរើសមុខ ឬ ក៏ការប្រើអាវុធក្នុងលក្ខណៈស្វ័យប្រវត្តិពេញលេញ នៅពេលនគរបាលរក្សាសណ្ដាប់ធ្នាប់អំឡុងពេលនៃការជួបជុំគ្នា។[134]

៨៩. រដ្ឋត្រូវទទួលខុសត្រូវនៅក្រោមច្បាប់អន្តរជាតិ ចំពោះសកម្មភាព និង អំពើអកម្មរបស់ភ្នាក់ងារប្រតិបត្តិច្បាប់របស់ខ្លួន។ ដោយមានគោលបំណងបង្ការការរំលោភបំពាននានា រដ្ឋទាំងឡាយត្រូវលើកកម្ពស់ឲ្យបានខ្ជាប់ខ្ជួននូវវប្បធម៌គណនេយ្យភាពរបស់មន្ត្រីប្រតិបត្តិច្បាប់ក្នុងអំឡុងពេលនៃការជួបជុំគ្នា។ ដើម្បីធ្វើឲ្យប្រសើរឡើងនូវគណនេយ្យភាព

129 S/2009/693, annex, para. 62; and UN Human Rights Guidance on Less-Lethal Weapons in Law Enforcement, para. 7.3.7.
130 ACHPR, *Guidelines on Policing Assemblies in Africa*, para. 21.2.4.
131 Basic Principles on the Use of Force and Firearms by Law Enforcement Officials, principle 14.
132 General comment No. 36, para. 12; Basic Principles on the Use of Force and Firearms by Law Enforcement Officials, Principles 9 and 14.
133 UN Human Rights Guidance on Less-Lethal Weapons in Law Enforcement, para. 7.5.8.
134 A/HRC/31/66, paras. 60, 67(e). See also OHCHR/UNODC, *Resource Book on the Use of Force and Firearms in Law Enforcement* (2017) p. 96.

ប្រកបដោយប្រសិទ្ធភាព មន្ត្រីប្រតិបត្តិច្បាប់ដែលមានឯកសណ្ឋានត្រូវបង្ហាញនូវអត្តសញ្ញាណកម្មដែលអាចសម្គាល់បានយ៉ាងងាយស្រួលអំឡុងពេលនៃការជួបជុំគ្នា។[135]

៩០. រដ្ឋមានកាតព្វកិច្ចក្នុងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ដោយមិនលំអៀង និង ទាន់ពេលវេលានូវរាល់ការចោទប្រកាន់ ឬ ការសង្ស័យសមហេតុផលណាមួយ នៃការប្រើប្រាស់កម្លាំងដោយមិនស្របច្បាប់ ឬ ការរំលោភផ្សេងៗដោយមន្ត្រីប្រតិបត្តិច្បាប់ រួមទាំងហិង្សាផ្លូវភេទ ឬហិង្សាផ្អែកយ៉េនឌ័រ នៅក្នុង បរិបទនៃការជួបជុំគ្នា។[136] ទាំងសកម្មភាព ឬ អសកម្មដោយចេតនា និង ការធ្វេសប្រហែសអាចបណ្តាលឲ្យមានការរំលោភសិទ្ធិមនុស្ស។ មន្ត្រីនីមួយៗដែលទទួលខុសត្រូវចំពោះការរំលោភត្រូវតែដាក់ឲ្យទទួលខុសត្រូវនៅក្រោមច្បាប់ក្នុងស្រុក និង ក្នុងករណីមានការពាក់ព័ន្ធគ្នា ច្បាប់អន្តរជាតិ និង ដំណោះស្រាយមានប្រសិទ្ធិភាពត្រូវតែអាចយកមកអនុវត្តសម្រាប់ជនរងគ្រោះ។[137]

៩១. រាល់ការប្រើប្រាស់កម្លាំងដោយមន្ត្រីប្រតិបត្តិច្បាប់ត្រូវកត់ត្រា និង ឆ្លុះបញ្ចាំងឲ្យបានឆាប់នៅក្នុងរបាយការណ៍មួយប្រកបដោយតម្លាភាព។ នៅពេលដែលការរងរបួស ឬ ការខូចខាតបានកើតឡើង របាយការណ៍មួយត្រូវមានព័ត៌មានគ្រប់គ្រាន់ ដើម្បីកំណត់ថាតើការប្រើប្រាស់កម្លាំងនោះមានភាពចាំបាច់ និង សមាមាត្រឬទេ ដោយរៀបរាប់ពិស្តារអំពីឧប្បត្តិហេតុ រួមទាំងហេតុផលនៃការប្រើប្រាស់កម្លាំង ប្រសិទ្ធភាព និងផលវិបាកនៃការប្រើប្រាស់កម្លាំង។[138]

៩២. រាល់ការដាក់ពង្រាយមន្ត្រីនគរបាលស៊ីវិលនៅអំឡុងពេលនៃការជួបជុំ ត្រូវតែមានភាពចាំបាច់បំផុត ស្ថិតក្រោមកាលៈទេសៈណាមួយ ហើយមន្ត្រីទាំងនោះមិនត្រូវញុះញង់ឲ្យមានអំពើហិង្សាឡើយ។ មុនពេលធ្វើការឃាត់ខ្លួន ការចាប់ខ្លួន រឺការប្រើកម្លាំងណាមួយមន្ត្រីនគរបាលស៊ីវិលត្រូវតែបង្ហាញអត្តសញ្ញាណរបស់ខ្លួនដល់ជនដែលពាក់ព័ន្ធ។

៩៣. រដ្ឋជាអ្នកទទួលខុសត្រូវចុងក្រោយក្នុងការប្រតិបត្តិច្បាប់ អំឡុងពេលនៃការជួបជុំគ្នា ហើយអាចផ្ទេរភារកិច្ចឲ្យអ្នកផ្តល់សេវាសន្តិសុខឯកជនបាន តែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ។ ក្នុងករណីបែបនោះ រដ្ឋនៅតែទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ពួកគេ។[139]

---

135 C.f. European Court of Human Rights, *Hentschel and Stark* v. *Germany* (application No. 47274/15), judgment of 9 November 2017, para. 91; CAT/C/DEU/CO/6, para. 40.

136 CCPR/C/COD/CO/4, paras. 43–44; CCPR/C/BHR/CO/1, para. 36. See also *The Minnesota Protocol on the investigation of potentially unlawful death (2016)* (United Nations publication, Sales No. E.91.IV.1).

137 A/RES/60/147, annex.

138 UN Human Rights Guidance on Less-Lethal Weapons in Law Enforcement, paras. 3.3–3.5.

139 General comment No. 36, para. 15.

នេះគឺជាការបន្ថែមទៅលើគណនេយ្យភាពរបស់អ្នកផ្តល់សេវាសន្តិសុខឯកជនដែលស្ថិតនៅក្រោមច្បាប់ក្នុងស្រុក ហើយក្នុងករណីពាក់ព័ន្ធ ក៏ស្ថិតនៅក្រោមច្បាប់អន្តរជាតិផងដែរ។[140] តួនាទី និង អំណាចរបស់អ្នកផ្តល់សេវាសន្តិសុខឯកជនក្នុងការប្រតិបត្តិច្បាប់គួរតែត្រូវបានកំណត់ដោយអាជ្ញាធរក្នុងច្បាប់ជាតិ និង ការប្រើប្រាស់កម្លាំង និង ការបណ្តុះបណ្តាលរបស់គេដែលមានបទប្បញ្ញត្តិយ៉ាងតឹងរឹង។[141]

៩៤. ការប្រើប្រាស់ឧបករណ៍ថតសំលេងដោយមន្ត្រីប្រតិបត្តិច្បាប់ក្នុងអំឡុងពេលជួបជុំគ្នារួមទាំងកាមេរ៉ាពាក់លើរាងកាយអាចដើរតួនាទីវិជ្ជមាន ក្នុងការធានាបូរគណនេយ្យភាពប្រសិនបើប្រើដោយឈ្លាសវៃនោះ។ ទោះយ៉ាងណាក៏ដោយ អាជ្ញាធរគួរតែមានគោលការណ៍ណែនាំច្បាស់លាស់ និង អាចប្រើបានជាសាធារណៈដើម្បីធានាថា ការប្រើប្រាស់របស់ពួកគេស្របនឹងស្តង់ដារអន្តរជាតិ ស្តីពីភាពឯកជន និង មិនមានផលប៉ះពាល់ដល់ការចូលរួមនៅក្នុងការជួបជុំគ្នាទេ។[142] អ្នកចូលរួមក៏ដូចជាអ្នកសារព័ត៌មាន និង អ្នកឃ្លាំមើលក៏មានសិទ្ធិកត់ត្រាសកម្មភាពរបស់មន្ត្រីប្រតិបត្តិច្បាប់ផងដែរ។[143]

៩៥. រដ្ឋទទួលខុសត្រូវទាំងស្រុង ចំពោះប្រព័ន្ធអាវុធដែលគ្រប់គ្រងពីចម្ងាយណាមួយដែលខ្លួនប្រើប្រាស់ក្នុងអំឡុងនៃការជួបជុំគ្នា។ វិធីសាស្រ្តនៃការប្រើប្រាស់កម្លាំងបែបនេះអាចបង្កើនឲ្យមានភាពតានតឹងកាន់តែខ្លាំង ហើយក៏អាចត្រូវបានប្រើប្រាស់ទៅបានដោយការប្រុងប្រយ័ត្នខ្ពស់តែប៉ុណ្ណោះ។ ប្រព័ន្ធអាវុធស្វយ័តពេញលេញដែលជាកម្លាំងដ៏ពិឃាតនោះអាចត្រូវបានគេប្រើប្រឆាំងនឹងអ្នកចូលរួមក្នុងការជួបជុំគ្នា ដោយគ្មានការធ្វើអន្តរាគមន៍ពីបុគ្គលសំខាន់ណាម្នាក់ នៅពេលដែលប្រព័ន្ធមួយនោះត្រូវបានគេដាក់ឲ្យប្រើប្រាស់នោះហើយនឹងមិនដែលត្រូវបានប្រើសម្រាប់ការប្រតិបត្តិច្បាប់ក្នុងអំឡុងពេលជួបជុំគ្នាឡើយ។[144]

## VII. ការជួបជុំគ្នាក្នុងអំឡុងពេលដាក់រដ្ឋក្នុងស្ថានភាពអាសន្ន និង ជំលោះប្រដាប់អាវុធ

៩៦. សិទ្ធិនៃការជួបជុំគ្នាដោយសន្តិវិធីមិនត្រូវបានចុះក្នុងបញ្ជីថាជាសិទ្ធិមួយ ដែលមិនអាចត្រូវបានគេដកហូតដូចបានចែងនៅត្រង់មាត្រា ៤ (២) នៃកតិកាសញ្ញានោះទេ ប៉ុន្តែសិទ្ធិផ្សេងៗទៀតដែលអាចអនុវត្តបានចំពោះការជួបជុំគ្នា ដូចជាសិទ្ធិដែលបានចែងត្រង់មាត្រា ៦ ៧ និង ១៨ គឺមិនអាចដកហូតបានឡើយ។ រដ្ឋភាគីនានាមិនត្រូវពឹងផ្អែកលើការដកហូតសិទ្ធិ ពីសិទ្ធិក្នុងការជួបជុំគ្នាដោយសន្តិវិធីនោះទេ ប្រសិនបើពួកគេអាចសម្រេចបានគោលបំណងរបស់ពួកគេ តាមរយៈការដាក់ការរឹតត្បិតដូចបានចែងត្រង់មាត្រា

140 C.f. *International Code of Conduct for Private Security Service Providers* (2010)
141 UN Human Rights Guidance on Less-Lethal Weapons in Law Enforcement, para. 3.2.
142 CCPR/C/CHN-HKG/CO/3, para. 10; CCPR/C/CHN-MAC/CO/1, para. 16.
143 A/HRC/31/66, para. 71.
144 Ibid., para. 67.

២១។[145] ប្រសិនបើរដ្ឋដកហូតសិទ្ធិពីកតិកាសញ្ញាជាការឆ្លើយតប ឧទាហរណ៍ មហាបាតុកម្មមួយដែលមានអំពើហិង្សាកើតឡើង រដ្ឋនោះត្រូវតែមានលទ្ធភាពផ្តល់នូវយុត្តិកម្មថា មិនត្រឹមតែថាស្ថានភាពបែបនេះបង្កការគំរាមកំហែងដល់អាយុជីវិតរបស់ប្រទេសជាតិនោះទេ ប៉ុន្តែរាល់វិធានការទាំងអស់ដែលដកហូតសិទ្ធិពីកាតព្វកិច្ចរបស់ពួកគេស្ថិតនៅក្រោមកតិកាសញ្ញា ក៏ជាលក្ខណ្ឌតម្រូវយ៉ាងតឹងរ៉ឹង ដែលត្រូវបញ្ជាក់ភាពចាំបាច់បន្ទាន់មួយនៃស្ថានភាព និង ត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចបានចែងត្រង់មាត្រា ៤។[146]

៩៧. នៅក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធ ការប្រើប្រាស់កម្លាំងអំឡុងពេលនៃការជួបជុំគ្នាដោយសន្តិវិធីនៅតែត្រូវបានកំណត់ដោយវិធាន ដែលគ្រប់គ្រងការប្រតិបត្តិច្បាប់ព្រមទាំងកតិកាសញ្ញាក៏នៅតែបន្តអនុវត្តដែរ។[147] ជនស៊ីវិលស្ថិតនៅក្នុងការជួបជុំគ្នាត្រូវបានការពារពីការកំណត់គោលដៅដោយកម្លាំងដែលងាយបង្កឲ្យគ្រោះថ្នាក់ដល់អាយុជីវិត លើកលែងតែ និងនៅពេលខ្លះ ដោយសារពួកគេចូលរួមដោយផ្ទាល់នៅក្នុងទង្វើអរិភាព ព្រោះអំឡុងពេលនោះត្រូវបានគេយល់ច្បាស់តាមច្បាប់មនុស្សធម៌អន្តរជាតិ (IHL) ។ ក្នុងកាលៈទេសៈបែបនេះពួកគេអាចត្រូវបានគេកំណត់គោលដៅ តែនៅក្នុងកម្រិតមួយដែលពួកគេមិនត្រូវបានការពារស្ថិតនៅក្រោមច្បាប់អន្តរជាតិពីការវាយប្រហារឡើយ។ ការប្រើប្រាស់កម្លាំងណាមួយ ដែលស្ថិតក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវអនុវត្តតាមវិធាន និង គោលការណ៍នៃភាពខុសគ្នា ការប្រុងប្រយ័ត្នក្នុងការវាយប្រហារ សមាមាត្រភាព ភាពចាំបាច់ខាងយោធា និង មនុស្សជាតិ។ រាល់សេចក្តីសម្រេចចិត្តទាំងឡាយណាក្នុងការការប្រើប្រាស់កម្លាំង សុវត្ថិភាព និង ការការពារអ្នកចូលរួមក្នុងការជួបជុំគ្នា និង សាធារណជនទូទៅគួរតែជាការពិចារណាមួយដ៏សំខាន់។

## VIII. ទំនាក់ទំនងរវាងមាត្រា ២១ និង បទប្បញ្ញត្តិផ្សេងទៀតនៃកតិកាសញ្ញា និង របបគតិយុត្តដទៃទៀត

៩៨. ការការពារពេញលេញនូវសិទ្ធិ នៃការជួបជុំគ្នាដោយសន្តិវិធី អាស្រ័យលើការការពារសិទ្ធិមួយចំនួន។ ការប្រើប្រាស់កម្លាំងដែលមិនចាំបាច់ ឬ មិនសមាមាត្រ ឬ ការប្រព្រឹត្តិខុសច្បាប់ផ្សេងៗទៀតដោយមន្ត្រីរដ្ឋក្នុងអំឡុងពេលនៃការជួបជុំគ្នាអាចរំលោភត្រង់មាត្រា ៦ មាត្រា ៧ និង ៩ នៃកតិកាសញ្ញា។[148] ករណីធ្ងន់ធ្ងរបំផុតមួយគឺនៅពេលដែលអ្នកចូលរួមនៅក្នុងការជួបជុំគ្នា ដោយសន្តិវិធីត្រូវបានទទួលរងដោយកម្លាំង ឬការប្រព្រឹត្តដែលមិនស្របច្បាប់ ដែលជាផ្នែកមួយនៃការវាយប្រហារដែលមានលក្ខណៈរាលដាល ឬ

[145] Ibid., para. 5; General comment No. 29, para. 5. See also CCPR/C/128/2, para. 2 (c).
[146] General comment No. 29, paras. 5–9.
[147] General comment No. 36, para. 64.
[148] CCPR/C/ISR/CO/3, para. 9; CCPR/C/UZB/CO/3, para. 8; and *Olmedo v. Paraguay* (CCPR/C/104/D/1828/2008), para. 7.5; *Benítez Gamarra v. Paraguay* (CCPR/C/104/D/1829/2008), para. 7.4.

ជាប្រព័ន្ធ ដែលតម្រង់ទិសដៅទៅលើប្រជាជនស៊ីវិលណាមួយ ក៏អាចគេចាត់ទុកផងដែរ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងករណីដែលលក្ខណៈវិនិច្ឆ័យពាក់ព័ន្ធផ្សេងទៀតត្រូវបានបំពេញ។[149]

៩៩. ការដាក់កម្រិតលើលទ្ធភាពរបស់ប្រជាជនក្នុងការធ្វើដំណើរ ដើម្បីចូលរួមក្នុងការជួបជុំគ្នា រួមទាំងការធ្វើដំណើរទៅបរទេស (មាត្រា ១២ (២)) និង ចូលរួមក្នុងការដើរក្បួន និងការជួបជុំគ្នាហែរក្បួនទៃទៀត ដែលអាចរំលោភបំពានសេរីភាពក្នុងការធ្វើដំណើរ (មាត្រា ១២ (១)) ។ ការសម្រេចចិត្តជាផ្លូវការដែលដាក់កម្រិតលើការអនុវត្តសិទ្ធិជួបជុំគ្នាត្រូវតែបើកចំហរឲ្យមានការតវ៉ាខាងផ្លូវច្បាប់ ក្នុងដំណើរការដែលឆ្លើយតបនឹងលក្ខណ្ឌតម្រូវនៃសវនាការមួយប្រកបដោយយុត្តិធម៌ និង ជាសាធារណៈ (មាត្រា ១៤ (១)) ។[150] ការឃ្លាំមើលអ្នកទាំងឡាយណាដែលចូលរួមក្នុងការជួបជុំគ្នា និងសកម្មភាពប្រមូលទិន្នន័យផ្សេងទៀតអាចរំលោភលើសិទ្ធិឯកជនរបស់ពួកគេ (មាត្រា ១៧) ។ ការជួបជុំខាងសាសនាក៏អាចត្រូវបានការពារ ដែលជាសេរីភាព ដើម្បីសម្តែងពីជំនឿ ឬ សាសនារបស់ពួកគេផងដែរ (មាត្រា ១៨) ។[151] សិទ្ធិនៃការជួបជុំគ្នាដោយសន្តិវិធីគឺមានលក្ខណៈលើសពីការសម្តែងសេរីភាពនៃការបញ្ចេញមតិទៅទៀត (មាត្រា ១៩ (២)) ប៉ុន្តែវាច្រើនតែមានធាតុផ្សំនិង សនិទានភាពមានអំណាចសម្តែង សម្រាប់ការទទួលស្គាល់សិទ្ធិទាំងពីរនេះ និង ការរឹតត្បិតដែលអាចទទួលយកបានត្រួតលើគ្នាតាមមធ្យោបាយជាច្រើន។ សេរីភាពក្នុងការទទួលបានព័ត៌មានដែលគ្រប់គ្រងដោយស្ថាប័នសាធារណៈ (មាត្រា ១៩ (២)) គូសបញ្ជាក់ពីសមត្ថភាពរបស់សាធារណជនក្នុងការយល់ដឹងអំពីក្របខ័ណ្ឌច្បាប់ និង រដ្ឋបាលដែលត្រូវអនុវត្តចំពោះការជួបជុំគ្នា និង អាចឲ្យពួកគេដាក់មន្ត្រីសាធារណៈឲ្យទទួលខុសត្រូវ។

១០០. សេរីភាពខាងសមាគម (មាត្រា ២២) ក៏ការពារសកម្មភាពសមូហភាពផងដែរ ហើយការរឹតត្បិតលើសិទ្ធិនេះ ច្រើនតែប៉ះពាល់ដល់សិទ្ធិនៃការជួបជុំគ្នាដោយសន្តិវិធី។ សិទ្ធិក្នុងការចូលរួមក្នុងនយោបាយ (មាត្រា ២៥) គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសិទ្ធិនៃការជួបជុំគ្នាដោយសន្តិវិធី ហើយក្នុងករណីដែលពាក់ព័ន្ធ ការរឹតត្បិតត្រូវតែផ្តល់យុត្តិកម្ម ស្ថិតក្រោមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២១ និង មាត្រា ២៥។[152] សិទ្ធិមិនរើសអើងការពារអ្នកចូលរួមពីទំលាប់អនុវត្តដែលមានលក្ខណៈការរើសអើងនៅក្នុងបរិបទនៃការជួបជុំគ្នា (មាត្រា ២ (១) ២៤ និង ២៦) ។

149 Rome Statute of the International Criminal Court, 1998, article 7.
150 *Evrezov et al. v. Belarus*, paras. 3.3 and 8.9.
151 See General comment No. 22, para. 8.
152 *Sudalenko v. Belarus*, para. 8.6.

១០១. នៅពេលដំណាលគ្នានេះ ការចូលរួមក្នុងការជួបជុំគ្នាដោយសន្តិវិធីក៏អាចត្រូវបាន គេរឹតត្បិត ស្របតាមមាត្រា ២១ ដើម្បីការពារសិទ្ធិ និង សេរីភាពរបស់អ្នកដទៃ។

១០២. សិទ្ធិជួបប្រជុំដោយសន្តិវិធីមានតម្លៃជាមូលដ្ឋាន។ លើសពីនេះទៅទៀត សិទ្ធិនេះ ច្រើនតែត្រូវបានអនុវត្តជាញឹកញាប់ក្នុងគោលបំណងជម្រុញការអនុវត្តសិទ្ធិមនុស្សផ្សេង ទៀត ក៏ដូចជាបទដ្ឋាន និងគោលការណ៍ដទៃទៀតនៃច្បាប់អន្តរជាតិ។ ក្នុងករណីបែប នេះ កាតព្វកិច្ចត្រូវគោរព និង ធានាសិទ្ធិនៃការជួបជុំគ្នាដោយសន្តិវិធីកើតចេញពីយុត្តិកម្ម ផ្លូវច្បាប់របស់ខ្លួនពីសារៈសំខាន់នៃជម្រើសដ៏ទូលំទូលាយនៃសិទ្ធិបទដ្ឋាន និង គោល ការណ៍ដទៃទៀតដែលធ្វើឲ្យមានវឌ្ឍនភាពក្នុងការអនុវត្ត។